**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2011, 15:27
CMS/CFO: Kauv Keoratanak

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការ ទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

---

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូន: |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | អៀង ធីរិទ្ធ |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម ធូ មណី | |

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | **មេធាវីការពារក្តីជនជាប់ចោទ:** |
| ពេជ អង្គ | លោក សុន អរុណ |
| Elisabeth SIMONNEAU FORT | លោក Michiel PESTMAN |
| | លោក Victor Koppe |
| | លោក អាង ឧត្តម |
| | លោក Michael G.KARNAVAS |
| | លោក ផាត់ ពៅស៊ាង |
| | កញ្ញា Diana ELLIS QC |
| | លោក ស សូវ៉ាន |
| | លោក Jacques VERGÈS |

## I. សេចក្តីផ្តើម

១- នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីដាក់បញ្ជីឈ្មោះ សាក្សី និងភ័ស្តុតាងរបស់ខ្លួនដែលបានស្នើឡើងដើម្បីរៀបចំសវនាការ[1]។ ជាការឆ្លើយតបទៅនឹងដីកានេះ អៀង សារី បានជូនព័ត៌មានដល់អង្គជំនុំជម្រះសាលាដំបូងថា ខ្លួនមានបំណងប្រើប្រាស់ "សិទ្ធិ" របស់ខ្លួន តទល់នឹងសាក្សីទាំងអស់ដែលផ្តល់សក្ខីកម្មប្រឆាំងនឹងរូបគាត់ និងជំទាស់នឹងការប្រើប្រាស់ចម្លើយរបស់សាក្សីណាមួយដែលនឹងមិនត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្ម[2]។ ស្រដៀង គ្នានេះដែរ អៀង ធីរិទ្ធ បានស្នើទៅអង្គជំនុំជម្រះសាលាដំបូង សុំឲ្យគាត់បានធ្វើការសាកសួរគ្រប់សាក្សីរបស់ភាគីបដិបក្ខទាំងឡាយណា ដែលគាត់មិនមានលទ្ធភាពជំទាស់កាលនៅដំណាក់កាលមុនពេលជំនុំជម្រះ បើចម្លើយនានារបស់ពួកគេត្រូវបានស្នើឲ្យដាក់បញ្ចូលធ្វើជាភ័ស្តុតាង[3]។ ខៀវ សំផន ក៏បានអះអាងការពារនូវសិទ្ធិក្នុងការស្នើសុំឲ្យកោះហៅសាក្សីណាក៏ដោយ(ដែលសាក្សីនោះផ្តល់សក្ខីកម្មប្រឆាំងនឹងគាត់ ហើយគាត់មិនមានកាលានុវត្តភាពក្នុងការពិនិត្យ ក្នុងអំឡុងពេលមុនសវនាការ)[4]។ ជាចុងក្រោយ នួន ជា បានបញ្ជាក់ថា គាត់ "រក្សាសិទ្ធិរបស់គាត់ ដើម្បីកោះហៅសាក្សីនានា និងសាក្សីដែលមានឈ្មោះនៅក្នុង...សេចក្តីថ្លែងជាបន្តរបន្ទាប់ដែលសហព្រះរាជអាជ្ញាបានផ្តល់ជូន (ឬភាគីដទៃទៀត) ហើយបានទទួលស្គាល់ដោយអង្គជំនុំជម្រះ"[5]។

២- ជាសេចក្តីសង្ខេប សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានដូចតទៅនេះ៖

(ក) ជនជាប់ចោទមិនមានសិទ្ធិដាច់ខាតណាមួយទេ ក្នុងការកោះហៅ និងសាកសួរសាក្សីនៅពេលសវនាការ។ អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី រួមទាំង កំណត់ហេតុទាំងឡាយណាដែលនឹងមិនផ្តល់សក្ខីកម្មអំពីអំពើ

---

[1] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ថ្ងៃទី១៧ មករា ២០១១, E9 ។

[2] ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលដាក់អមជាមួយនឹងបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០, ថ្ងៃទី៨ កុម្ភៈ ២០១១, E9/4/1, កថាខណ្ឌទី ២ ។

[3] សេចក្តីបញ្ជាក់របស់ អៀង ធីរិទ្ធ អំពីចេតនាជំទាស់ទៅនឹងសាក្សី និងអ្នកជំនាញដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះសាក្សីរបស់សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និង នួន ជា, ថ្ងៃទី២៨ កុម្ភៈ ២០១១, E9/4/11, កថាខណ្ឌទី ៤, ៦ និង ២៦ ។ សំណើរបស់អ្នកស្រី អៀង ធីរិទ្ធ សុំដាក់បញ្ចីឯកសាររបស់ខ្លួន, ថ្ងៃទី១៩ មេសា ២០១១, E9/27, កថាខណ្ឌទី ៦ ។

[4] បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញដែលបានស្នើឡើង, ថ្ងៃទី២១ កុម្ភៈ ២០១១, E9/4/6, កថាខណ្ឌទី ១១ និង ១៣ ។

[5] បញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារលេខE9/4/4 កថាខណ្ឌទី៨

និងអាកប្បកិរិយារបស់ជនចាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយមិនមានធ្វើការកោះហៅសាក្សី ដើម្បីឲ្យមកផ្តល់សក្ខីកម្មនៅពេលសវនាការឡើយ។

(ខ) អង្គជំនុំជម្រះសាលាដំបូង អាចនឹងអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីណាម្នាក់បាន និងតម្រូវឲ្យសាក្សីរូបនោះចូលមកបង្ហាញខ្លួន ដើម្បីធ្វើការសាកសួរនៅពេលសវនាការ បើកំណត់ហេតុស្តាប់ចម្លើយនោះទាក់ទងទៅនឹង៖ ទី១) អំពើ និងអាកប្បកិរិយារបស់អ្នកនៅក្រោមបង្គាប់ផ្ទាល់ណាមួយដែលនៅក្បែរជនជាប់ចោទ ឬ ទី២) បញ្ហាស្នូលនៅក្នុងរឿងក្តីនោះ។

(គ) ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះគួរតែត្រូវបានធ្វើតាមការណែនាំពី៖ ទី១) ករណីយកិច្ចដែលសំខាន់ជាងអ្វីៗឯទៀតរបស់អង្គជំនុំជម្រះ ដើម្បីធានាឲ្យមានការជំនុំជម្រះមួយដែលត្រឹមត្រូវ, ទី២) គោលការណ៍ផ្សេងៗទៀតរបស់ខ្លួនដែលគ្រប់គ្រងលើដំណើរការនីតិវិធី ដូចជា កាតព្វកិច្ចរបស់អង្គជំនុំជម្រះ ក្នុងការការពារផលប្រយោជន៍របស់ជនរងគ្រោះ ជាដើម ទី៣) នីតិវិធីប្រព័ន្ធច្បាប់ស៊ីវិលជាធរមាននៅចំពោះមុខ អវតក ដែលបានសង្កត់ធ្ងន់យ៉ាង សំខាន់ទៅលើការប្រើប្រាស់នូវកំណត់ត្រាជាលាយលក្ខណ៍អក្សរនានា ដែលចៅក្រមស៊ើប អង្កេតបានប្រមូល, ទី៤) គោលការណ៍អន្តរជាតិនានាដែលបានអំពាវនាវឲ្យមានវិធីសាស្ត្រមួយដែលមានលក្ខណៈបត់បែន ក្នុងការទទួលយកនូវភ័ស្តុតាង នៅក្នុងករណីនានាដែលមានបទឧក្រិដ្ឋដ៏រង្គាល និងទី៥) វិសាលភាពនៃរឿងក្តី និងចរិតលក្ខណៈនៃការលើកឡើងចោទប្រកាន់លើជនជាប់ចោទ។

(ឃ) អង្គជំនុំជម្រះសាលាដំបូង គួរតែធ្វើការវាយតម្លៃលើកំណត់ហេតុស្តាប់ចម្លើយនានា ជាដំណាក់កាល បែបដូចជាដំណើរការនីតិវិធីផ្តល់ភ័ស្តុតាងកំពុងតែប្រព្រឹត្តទៅដូច្នោះដែរ និង និងវិធានអំពីសេចក្តីត្រូវការចាំបាច់របស់សាក្សីដែលត្រូវហៅមកឲ្យផ្តល់សក្ខីកម្ម មុនដំណាក់កាលនីមួយៗក្នុងរឿងក្តីនេះ។

## II. អំពីច្បាប់

*វិធាន និងបទប្បញ្ញត្តិច្បាប់ជាធរមាន នៅចំពោះមុខ អវតក*

៣- មានភាពមិនរលូនមួយចំនួនរវាងភាសាទាំងបីនៅក្នុងអនុវិធាន ៨៤.១[6] ។ វិធានជាភាសាអង់គ្លេសចែងថា៖

> ជនជាប់ចោទមានសិទ្ធិដាច់ខាតស្នើសុំឲ្យកោះហៅសាក្សីដាក់បន្ទុកដែលជនជាប់ចោទ មិនទាន់មានឱកាសតទល់នៅដំណាក់កាលមុនពេលជំនុំជម្រះ។

វិធានជាភាសាខ្មែរ ដែលបានបកប្រែទៅជាភាសាអង់គ្លេស គឺមានដូចតទៅ៖

> ជនជាប់ចោទមានសិទ្ធិស្នើសុំឲ្យកោះហៅសាក្សីដាក់បន្ទុកដែលជនជាប់ចោទ មិនទាន់មានឱកាសតទល់នៅដំណាក់កាលមុនពេលជំនុំជម្រះ។

វិធានជាភាសាបារាំង ដែលបានបកប្រែទៅជាភាសាអង់គ្លេស គឺមានពាក្យពេចន៍ដូចតទៅ៖

> ជនជាប់ចោទមានសិទ្ធិស្នើសុំឲ្យកោះហៅសាក្សីណាក៏ដោយ ដែលជនជាប់ចោទមិនធ្លាប់មានឱកាសតទល់នៅដំណាក់កាលមុនពេលជំនុំជម្រះ/ក្នុងអំឡុងពេលស៊ើបសួរ[7] ។

៤- គឺមានតែអត្ថបទជាភាសាអង់គ្លេសប៉ុណ្ណោះទេ ដែលរៀបរាប់ពីសិទ្ធិរបស់ជនចាប់ចោទក្នុងការស្នើសុំឲ្យកោះហៅសាក្សី ថាជាសិទ្ធិ "ដាច់ខាត"។ គុណនាមនេះមិនមានវត្តមានទេ នៅក្នុងអត្ថបទជាភាសាខ្មែរ ឬបារាំង ក្នុងវិធានផ្ទៃក្នុង។ អត្ថបទជាភាសាបារាំងក៏មិនមានពាក្យ "ដាក់បន្ទុក" ដែរ។ អត្ថន័យនៃប្រយោគនេះខ្លួនឯង គឺមានលក្ខណៈស្រពិចស្រពិល។ វាមិនច្បាស់លាស់ទេថាវា៖ ទី១ សំដៅដល់សាក្សីទាំងឡាយណាដែលផ្តល់តែសក្ខីកម្មអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទប៉ុណ្ណោះ, ឬមួយក៏ ទី២) ក្តោបទាំងសាក្សីទាំងឡាយណាដែលផ្តល់ភស្តុតាងគាំទ្រដល់ករណីនៃការចោទប្រកាន់យ៉ាងទូលំទូលាយផងដែរ (ឧទា. សាក្សី[ដែលផ្តល់សក្ខីកម្មអំពី]ទីតាំងឧក្រិដ្ឋកម្ម)[8]។

---

[6] ភាសាទាំងបីនៃវិធានផ្ទៃក្នុង គឺមានសមភាពខាងផ្លូវច្បាប់៖ *សូមមើល* ច្បាប់ អវតក, មាត្រា ៤៥ថ្មី ។

[7] ការបកប្រែពីភាសាខ្មែរ និងបារាំង ត្រូវបានអង្គភាពបកប្រែភាសារបស់ អវតក ផ្តល់ឲ្យនៅថ្ងៃទី១៩ ឧសភា ២០១១ ។

[8] Guido Acquaviva: *ផ្លូវថ្មីនៅក្នុងយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ - វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,* ទិនានុប្បវត្តិយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ, ៦ ១ (១២៩) ២០០៨, ទំព័រទី ៩ ។

ស្របៀងគ្នានេះដែរ មាត្រា ២៩៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានប្រើគុណនាម "ដាក់បន្ទុក" ក៏ប៉ុន្តែមិនបានផ្តល់នូវសេចក្តីណែនាំបន្ថែមទៀតឡើយ[9]។ បើសិនជាត្រូវបានធ្វើការបកស្រាយដើម្បីផ្តល់នូវ "សិទ្ធិដាច់ខាត"មួយ នោះអនុវិធាន ៨៤.១ មុខជានឹងមិនមានភាពរលូនជាមួយនឹងអនុវិធាន ២១.១.ក នោះទេ ដែលការណ៍នេះតម្រូវឱ្យអង្គជំនុំជម្រះធ្វើការរក្សានូវតុល្យភាពរវាងសិទ្ធិនានារបស់ភាគីផ្សេងៗ។ វាក៏មុខជានឹងមិនមានភាពរលូនផងដែរ ជាមួយនឹងវិធីសាស្ត្រដែលត្រូវបានប្រកាន់យកនៅកម្រិតអន្តរជាតិ ដែលនឹងត្រូវបានធ្វើការពិភាក្សានៅខាងក្រោមនេះ។

៥- នីតិវិធីនៅចំពោះមុខ អវតក នៅមាន*ចន្លោះប្រហោង (lacunae)* មួយចំនួន៖ គឺវាមិនដូចគ្នាទៅនឹងវិធាននៃតុលាការអន្តរជាតិពិសេស *(ad hoc)* ទេ វិធានផ្ទៃក្នុងនេះ គឺមិនមានចែងអំពីបទប្បញ្ញត្តិ ស្តីពីការទទួលយកកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹកពីសវនាការផ្សេងៗទៀតនោះឡើយ។ គេឃើញមានគោលការណ៍ទូទៅជាធរមានស្តីពីការទទួលយកភ័ស្តុតាង នៅក្នុងអនុវិធាន ៨៧.១ ដែលចែងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេង...រាល់ភ័ស្តុតាងទាំងអស់ត្រូវតែទទួលយក"។ វិធានមិនបានចែងថាតើអង្គជំនុំជម្រះត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីដោះស្រាយអំពីទំនាក់ទំនងរវាងអនុវិធាន ៨៧.១ និង ៨៤.១ នោះឡើយ។ វិធាននេះក៏មិនបានដោះស្រាយឱ្យបានជាក់លាក់ផងដែរ លើការទទួលយកកំណត់ហេតុស្តាប់ចម្លើយនៅមុនពេលជំនុំជម្រះ ចំពោះសាក្សីដែលស្លាប់ សាក្សីដែលមិនអាចរកទីកន្លែងឃើញ ឬបើពុំនោះទេ សាក្សីដែលមិនអាចចូលរួមសវនាការបាន។

៦- ដោយហេតុថា នីតិវិធីដែលមានស្រាប់មិនបានដោះស្រាយឱ្យបានទូលំទូលាយលើបញ្ហាស្តីពីការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ហើយថាវាមានភាពមិនពិតប្រាកដពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តនូវនីតិវិធីទាំងនេះ និងមានបញ្ហាមួយដែលលើកឡើងពីភាពរលូននៃនីតិវិធីទាំងនេះជាមួយនឹងបទដ្ឋានអន្តរជាតិនោះ អង្គជំនុំជម្រះសាលាដំបូងគួរតែធ្វើការស្វែងរកនូវសេចក្តីណែនាំនៅក្នុងវិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ[10]។

[9] មាត្រានេះចែងថា៖ "សាក្សីខាងដាក់បន្ទុកដែលមិនទាន់បានសួរចម្លើយតទល់គ្នាជាមួយជនជាប់ចោទ ត្រូវតែកោះហៅឱ្យចូលធ្វើសក្ខីកម្មក្នុងសវនាការ" ។

[10] មាត្រា៣៣ថ្មី នៃច្បាប់ អវតក ។

## យុត្តិសាស្ត្រផ្នែកសិទ្ធិមនុស្ស

៧- មាត្រា ៦.៣.ឃ នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សនៅអ៊ឺរ៉ុប ដែលបានប្រើពាក្យពេចន៍ស្រដៀងគ្នានឹង អនុវិធាន ៨៤.១ នោះ បានចែងថា៖

៣. ជនណាដែលត្រូវបានចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិអប្បបរមាដូចតទៅ៖

(ឃ) សាកសួរ ឬឱ្យគេសាកសួរសាក្សីដាក់បន្ទុកនានា ព្រមទាំងទទួលបាននូវការចូលរួម និង ការសាកសួរសាក្សីដោះបន្ទុកនានា ដែលត្រូវស្ថិតនៅក្រោមលក្ខខណ្ឌច្បាប់ស្មើគ្នានឹង សាក្សីដាក់បន្ទុកដែរ។

៨-មាត្រា ១៤.៣.ង នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងថា៖

៣. ក្នុងការកំណត់ពីបទចោទព្រហ្មទណ្ឌណាមួយក៏ដោយទៅលើជនណាម្នាក់ ជននោះត្រូវមានសិទ្ធិ ស្មើៗគ្នាយ៉ាងពេញលេញ ក្នុងការទទួលបាននូវកិច្ចធានាអប្បបរមា ដូចតទៅ៖

(ង) សាកសួរ ឬឱ្យគេសាកសួរសាក្សីដាក់បន្ទុកនានា ព្រមទាំងទទួលបាននូវការចូលរួម និង ការសាកសួរសាក្សីដោះបន្ទុកនានា ដែលត្រូវស្ថិតនៅក្រោមលក្ខខណ្ឌច្បាប់ស្មើគ្នានឹង សាក្សីដាក់បន្ទុកដែរ។

៩-តុលាការសិទ្ធិមនុស្សនៅអ៊ឺរ៉ុប("ECtHR") បានសម្រេចថាសិទ្ធិរបស់ជនជាប់ចោទក្នុងការសាកសួរ សាក្សីនានាដែលចម្លើយរបស់ខ្លួនត្រូវបានទទួលយកធ្វើជាភ័ស្តុតាង គឺមិនមែនជាសិទ្ធិដែលឥតមាន កម្រិតនោះទេ។ ជាគោលការណ៍ ខណៈដែលការកាត់សេចក្តីដ៏ត្រឹមត្រូវមួយ អាចសម្រេចបាន ដោយ ជោគជ័យបំផុត ដោយមានរាល់ភ័ស្តុតាងទាំងអស់ត្រូវបានផ្តល់នៅក្នុងអំឡុងពេលសវនាការនោះ "ការ ប្រើប្រាស់នូវភ័ស្តុតាងដែលជាកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលបានមកនៅដំណាក់កាលស៊ើបសួរ គឺខ្លួនវាផ្ទាល់ មិនមែនមិនត្រូវគ្នាទៅនឹងមាត្រា ៦.១ និង ៦.៣.ឃ" នោះឡើយ ដោយបានចែងថា៖ ទី១) ជនជាប់ចោទធ្លាប់មាន "កាលានុវត្តភាពមួយដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប" ដើម្បីធ្វើការជំទាស់ទៅនឹងភ័ស្តុតាងដាក់បន្ទុក, និង ទី២) កំណត់ហេតុស្តាប់ចម្លើយសាក្សី គឺមិនបាន

ពឹងផ្អែកលើ "កម្រិតមួយដែលមានលក្ខណៈតែឯកឯង ឬដាច់ខាត" ឲ្យបានដូចជាកម្រិតភ័ស្តុតាងសម្រាប់ការកាត់ឲ្យជាប់ទោសនោះទេ[11]។

១០- ការសាកល្បងខាងលើនេះអនុវត្តនៅក្នុងករណីរបស់ *Asch ទល់នឹង Austria* និងករណីរបស់ *Artner ទល់នឹង Austria* តុលាការ ECtHR បានដោះស្រាយលើបណ្តឹងឧទ្ធរណ៍នានាដែលបានដាក់ដោយជនជាប់ចោទដែលត្រូវបានកាត់ឲ្យជាប់ទោស ដោយមានមូលដ្ឋាននៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលត្រូវបានធ្វើបមាណីករណ៍ ដោយភ័ស្តុតាងផ្សេងៗទៀត។ ក្នុងករណីរបស់ *Asch* តុលាការ ECtHR បានរកឃើញថា វាមិនមានការបំពានលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការកាត់សេចក្តីមួយដ៏ត្រឹមត្រូវនោះទេ។ នៅក្នុងករណីរបស់ *Asch* ដោយហេតុថា ដើមបណ្តឹងឧទ្ធរណ៍ត្រូវបានគេប្រឹងប្រែងផ្តល់នូវកាលានុវត្តភាពមួយឲ្យ ដើម្បីធ្វើការជំទាស់ទៅនឹងព្រឹត្តិការណ៍នានាតាមបែបដែលជនរងគ្រោះរៀបរាប់ និងដោយហេតុថា កំណត់ហេតុស្តាប់ចម្លើយមិនបង្កើតបានជាភ័ស្តុតាងតែមួយគត់ នៅចំពោះមុខតុលាការជំនុំជម្រះក្តី នោះគឺវានៅបើកចំហរឲ្យតុលាការទទួលយកវាធ្វើជាភ័ស្តុតាង។ អង្គហេតុពិតដែលថាជនរងគ្រោះមិនត្រូវបានគេសាកសួរនៅពេលសវនាការ មិនបានបំពានទៅលើសិទ្ធិរបស់មេធាវីការពារក្តីនោះឡើយ[12]។ នៅក្នុងករណីរបស់ *Artner* តុលាការ ECtHR បានសម្រេចស្រដៀងគ្នានេះដែរថា វាមានការបើកចំហរក្នុងការពឹងផ្អែកលើកំណត់ហេតុស្តាប់ចម្លើយសាក្សី ដរាបណា សិទ្ធិរបស់មេធាវីការពារក្តីត្រូវបានគេគោរព "ដោយឡែក តាមទស្សនៈនៃអង្គហេតុពិតដែលថា តុលាការអាចពិចារណាលើកំណត់ហេតុទាំងនោះបាន ដើម្បីឲ្យត្រូវបានធ្វើបមាណីករណ៍ ដោយភ័ស្តុតាងផ្សេងៗទៀតនៅចំពោះមុខខ្លួន"[13]។ នៅក្នុងករណីរបស់ *Saidi ទល់*

---

[11] ឧទាហរណ៍ រួមមាន *Unterpertinger ទល់នឹង ប្រទេសអូទ្រីស,* ថ្ងៃទី២៤ វិច្ឆិកា ១៩៨៦, ពាក្យសុំលេខ ៩១២០/៨០, កថាខណ្ឌទី ៣១ ។ *Windisch ទល់នឹង ប្រទេសអូទ្រីស,* ថ្ងៃទី២៧ កញ្ញា ១៩៩០, ពាក្យសុំលេខ ១២៤៨៩/៨៦, កថាខណ្ឌទី ២៦ និង ៣១ ។ *Delta ទល់នឹង ប្រទេសបារាំង,* ថ្ងៃទី១៩ ធ្នូ ១៩៩០, ពាក្យសុំលេខ ១១៤៤៤/៨៥, កថាខណ្ឌទី ៣៦-៣៧ ។ *Asch ទល់នឹង ប្រទេសអូទ្រីស,* ថ្ងៃទី២៦ មេសា ១៩៩១, ពាក្យសុំលេខ ១២៣៩៨/៨៦ ("សាលក្រមលើករណីរបស់ Asch"), កថាខណ្ឌទី ២៥, ២៧ និង ៣០ ។ *Saidi ទល់នឹង ប្រទេសបារាំង,* ថ្ងៃទី២០ កញ្ញា ១៩៩៣, ពាក្យសុំលេខ ១៤៦៤៧/៨៩ ("សាលក្រមលើករណីរបស់ Saidi"), កថាខណ្ឌទី ៤៣ ។ *Van Mechelen និង អ្នកដទៃទៀត ទល់នឹង ប្រទេសហុល្លង់,* ថ្ងៃទី១៨ មីនា ១៩៩៧, សំណុំរឿងលេខ 55/1996/674/861-864, កថាខណ្ឌទី ៤៩, ៥១, ៥៥ និង ៧៦ ។ *Luca ទល់នឹង ប្រទេសអ៊ីតាលី,* ថ្ងៃទី២៧ កុម្ភៈ ២០០១, ពាក្យសុំលេខ ៣៣៣៥៤/៩៦, កថាខណ្ឌទី ៣៧ និង ៣៩-៤០ ។ *ហើយនិង A.S. ទល់នឹង ប្រទេសហ្វាំងឡង់,* ថ្ងៃទី២៨ កញ្ញា ២០១០, ពាក្យសុំលេខ ៤០១៥៦/០៧, កថាខណ្ឌទី ៥៣-៥៤ ។

[12] សាលក្រមលើករណីរបស់ Asch, កថាខណ្ឌទី ២៧-៣០ ។

[13] *Artner ទល់នឹង ប្រទេសអូទ្រីស,* ថ្ងៃទី២៥ មិថុនា ១៩៩២, សំណុំរឿងលេខ ៣៩/១៩៩១/២៩១/៣៦២, ("សាលក្រមលើករណីរបស់ Artner"), កថាខណ្ឌទី ២១-២៤ ។

*នឹង ប្រទេសបារាំង* តុលាការ ECtHR បានសម្រេចថាការកាត់ឲ្យជនជាប់ចោទជាប់ទោស ដោយមានមូលដ្ឋាននៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សីនោះ បណ្តាលឲ្យមានការបំពានមួយទៅលើសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវការកាត់សេចក្តីមួយដ៏ត្រឹមត្រូវ ពីព្រោះថាកំណត់ហេតុស្តាប់ចម្លើយទាំងនោះបង្កើតបានជាមូលដ្ឋានតែមួយគត់សម្រាប់ការកាត់ឲ្យជាប់ទោស[14]។

១១- វាមានការពាក់ព័ន្ធដែលត្រូវធ្វើការកត់សម្គាល់ថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) បានលើកស្ទួយគោលការណ៍នេះឡើង ដែលថាវាមិនមានសិទ្ធិដាច់ខាតអ្វីមួយឡើយ ក្នុងការសាកសួរទៅលើរាល់សាក្សីបដិបក្ខទាំងអស់នៅពេលសវនាការ និងបានរកឃើញថា ការពឹងផ្អែកទៅលើយុត្តិសាស្ត្ររបស់តុលាការ ECtHR ចំពោះបញ្ហានេះ គឺជាការមួយដែលសមស្រប[15]។

## *តុលាការព្រហ្មទណ្ឌអន្តរជាតិ*

១២-វិធានស្តីពីភស្តុតាង និងនីតិវិធីរបស់តុលាការ ICTY មានបទប្បញ្ញត្តិទូទៅមួយស្តីពីការទទួលយកភស្តុតាង ដែលស្រដៀងគ្នាទៅនឹងអនុវិធាន ៨៧.១ នៃវិធានផ្ទៃក្នុងសម្រាប់អវតក។ វិធាន ៨៩.គ នៃវិធានស្តីពីភស្តុតាង និងនីតិវិធី ចែងថា "អង្គជំនុំជម្រះអាចនឹងទទួលយកភស្តុតាងពាក់ព័ន្ធណាមួយក៏ដោយ ដែលវាសមនឹងចាត់ទុកថាមានតម្លៃជាភស្តុតាង"[16]។

១៣- ទោះជាយ៉ាងដូច្នេះក៏ដោយ ក៏វិធានស្តីពីភស្តុតាង និងនីតិវិធី បានដោះស្រាយយ៉ាងជាក់លាក់ផងដែរអំពីការទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី។ នៅក្នុងផ្នែកដែលពាក់ព័ន្ធ វិធាន ៩២*ស្ទួន* បានចែងថា៖

---

[14] សាលក្រមលើករណីរបស់ Saidi, កថាខណ្ឌទី ៤៣-៤៤ ។

[15] *រដ្ឋអាជ្ញា ទល់នឹង Martic,* សំណុំរឿងលេខ IT-95-11-AR73.2, សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីភស្តុតាងរបស់សាក្សីឈ្មោះ Milan Babic, ថ្ងៃទី១៤ កញ្ញា ២០០៦, កថាខណ្ឌទី ១២-១៤ និង ១៨-១៩ ។ *សូមមើលផងដែរ, រដ្ឋអាជ្ញា ទល់នឹង Lukic,* សំណុំរឿងលេខ IT-98-32/1-T, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា ស្នើសុំឲ្យទទួលយកភស្តុតាង អនុលោមតាមវិធាន ៩២*ស្ទួន*, ថ្ងៃទី២២ សីហា ២០០៨, កថាខណ្ឌទី ២៤ ។

[16] ភស្តុតាងមិនត្រូវបានរាប់បញ្ចូល បើតម្លៃជាភស្តុតាងរបស់វាមានតម្លៃធ្ងន់ជាងយ៉ាងខ្លាំង លុបលើសេចក្តីត្រូវការក្នុងការធានាឲ្យមានការកាត់សេចក្តីមួយដ៏ត្រឹមត្រូវ (អនុវិធាន ៨៩.ឃ) ។

(ឆ) អង្គជំនុំជម្រះសាលាដំបូង អាចនឹងចែកការចូលរួមជាបុគ្គលឱ្យទៅសាក្សី ហើយផ្ទុយទៅវិញ អាចនឹងទទួលយក ទាំងស្រុង ឬ មួយផ្នែក នូវភ័ស្តុតាងរបស់សាក្សីណាម្នាក់ ក្នុងទម្រង់ជា កំណត់ហេតុស្តាប់ចម្លើយ ឬជាប្រតិចារឹកនៃភ័ស្តុតាង ដែលត្រូវបានផ្តល់ឱ្យដោយសាក្សីណាម្នាក់នៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះនោះ ជាការជំនួសឱ្យ សក្ខីកម្មផ្ទាល់មាត់ ដែលត្រូវប្រើធ្វើជាតឹកតាងលើបញ្ហាអ្វីមួយក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនចាប់ចោទដូចដែលត្រូវបានចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

(i) កត្តានានាដែលស្របទៅនឹងការទទួលយកភ័ស្តុតាងក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ ឬជាប្រតិចារឹកនៃភ័ស្តុតាង រួមមាន ក៏ប៉ុន្តែមិនកំណត់ត្រឹមតែកាលៈទេសៈនៃភ័ស្តុតាងនោះទេ៖

(ក) មានចរិតលក្ខណៈត្រួតគ្នា ដែលនៅក្នុងនោះសាក្សីដទៃទៀតនឹងផ្តល់ ឬបានផ្តល់រួចហើយនូវសក្ខីកម្មផ្ទាល់មាត់លើអង្គហេតុស្រដៀងគ្នា។

(ខ) មានការទាក់ទងនឹងសាវតារជាប្រវត្តិសាស្ត្រ ជានយោបាយ ឬជាយោធា ដែលមានការពាក់ព័ន្ធ។

(គ) មានការវិភាគមួយជាទូទៅ ឬជាស្ថិតិ ស្តីពីសមាសភាគជាតិពន្ធុនៃប្រជាជននៅតាមទីកន្លែងនានា ដែលមានការទាក់ទងដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

(ឃ) មានការបារម្ភពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ។

(ង) មានការទាក់ទងនឹងបញ្ហានានាស្តីពីអាកប្បកិរិយារបស់ជនរងគ្រោះ, ឬមួយក៏

(ច) មានការទាក់ទងនឹងកត្តានានាដែលគេត្រូវយកមកពិចារណានៅក្នុងការកំណត់ទោស។

(ii) កត្តានានាដែលមិនស្របទៅនឹងការទទួលយកភ័ស្តុតាងក្នុងទម្រង់ជា កំណត់ហេតុស្តាប់ចម្លើយ ឬជាប្រតិចារឹកនៃភ័ស្តុតាង រួមមាន ក៏ប៉ុន្តែមិនកំណត់ត្រឹមតែថាតើ៖

(ក) មានផលប្រយោជន៍សាធារណៈដ៏លើសលប់ នៅក្នុងភ័ស្តុតាងដែលត្រូវបង្ហាញដោយផ្ទាល់មាត់។

(ខ) ភាគីជំទាស់អាចបង្ហាញបានថា ចរិតលក្ខណៈ និង ប្រភពរបស់វា មិនអាចធ្វើឱ្យគេទុកចិត្តវាបាន ឬបង្ហាញថា អានុភាពបុរេវិនិច្ឆ័យ មានតម្លៃធ្ងន់ជាង តម្លៃជាភស្តុតាងរបស់វា, ឬមួយក៏

(គ) មានកត្តាផ្សេងៗទៀត ដែលធ្វើឱ្យវាមានលក្ខណៈសមស្របចំពោះសាក្សីរូបនោះ ចូលមកបង្ហាញខ្លួនសម្រាប់ការសាកសួរសាក្សីបដិបក្ខ។

...

(ឝ) បន្ទាប់ពីបានស្តាប់ភាគីនានារួចហើយ អង្គជំនុំជម្រះសាលាដំបូង ត្រូវសម្រេចថាតើត្រូវឱ្យសាក្សីចូលមកបង្ហាញខ្លួន ដើម្បីឱ្យមានការសាកសួរសាក្សីបដិបក្ខដែរ ឬទេ។ បើសិនជាត្រូវធ្វើដូច្នោះ នោះគេត្រូវអនុវត្តបទប្បញ្ញត្តិនានានៃវិធាន ៩២*ស្ទួន៣* ។

១៤-វិធាន ៩២*ស្ទួន* បានប្រគល់ឆន្ទានុសិទ្ធិឱ្យដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលមានភស្តុតាងពីមូលដ្ឋានឧក្រិដ្ឋកម្ម ដោយមិនតម្រូវឱ្យសាក្សីរូបនោះចូលមកបង្ហាញខ្លួន ដើម្បីធ្វើការសាកសួរនោះឡើយ[17]។ ការអនុវត្តនូវឆន្ទានុសិទ្ធិនេះ តម្រូវឱ្យមានការវាយតម្លៃជា៣ដំណាក់កាល៖

(ក) ទីមួយ ភស្តុតាងនោះត្រូវតែមានតម្លៃជាភស្តុតាងប្រកបដោយភាព ដែលវាមិនមានតម្លៃធ្ងន់ជាងដោយសារបុរេវិនិច្ឆ័យទៅលើជនជាប់ចោទ ឬទៅលើសិទ្ធិរបស់គាត់នៅក្នុងការទទួលបាននូវការកាត់សេចក្តីមួយដ៏ត្រឹមត្រូវនោះទេ។

(ខ) ទីពីរ ភស្តុតាងនោះមិនត្រូវប្រើធ្វើជាតឹកតាងលើអំពើ និងអាកប្បកិរិយារបស់ជនចាប់ចោទដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ហើយអង្គជំនុំជម្រះគួរតែពិចារណាលើកត្តានានាដែលផ្តល់សំអាងស្រប និងមិនស្រប ទៅនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយនោះ។

(គ) ទីបី បើសម្រេចថាត្រូវទួលយកភស្តុតាងជាលាយលក្ខណ៍អក្សរនោះ អង្គជំនុំជម្រះត្រូវតែពិចារណាថា តើវាតម្រូវឱ្យមានការចូលមកបង្ហាញខ្លួន ដើម្បីធ្វើការសាកសួរសាក្សីបដិបក្ខដែរ ឬទេ[18]។

[17] *រដ្ឋអាជ្ញា ទល់នឹង Galic,* សំណុំរឿងលេខ IT-98-29-AR73.2, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំពាក់ព័ន្ធនឹងវិធាន ៩២*ស្ទួន*.ឝ), ថ្ងៃទី៧ មិថុនា ២០០២, កថាខណ្ឌទី ១៦ (“សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Galic”) ។

[18] ចំពោះរូបមន្តនៃវិធីសាស្ត្រដែលស្រដៀងគ្នានេះ, *សូមមើល រដ្ឋអាជ្ញា ទល់នឹង Popovic និងអ្នកដទៃទៀត,* សំណុំរឿងលេខ IT-05-88-T, សេចក្តីសម្រេចលើញត្តិ *សម្ងាត់* របស់រដ្ឋអាជ្ញា ស្នើសុំឱ្យទទួលយកភស្តុតាងជាលាយលក្ខណ៍អក្សរ ជាជំនួសឱ្យសក្ខីកម្ម*ដោយផ្ទាល់មាត់* (*Viva Voce* Testimony) ដោយអនុលោមតាមវិធាន ៩២*ស្ទួន*, ថ្ងៃទី១២ កញ្ញា ២០០៦, កថាខណ្ឌទី ៨-៩ ។

១៥-ផ្នែក**ទីមួយ** នៃការធ្វើតេស្តល្បងពិសោធន៍ គ្រាន់តែផ្ដល់នូវអានុភាពដល់គោលការណ៍ដែលថា រាល់ភ័ស្តុតាងទាំងអស់ តោងតែបំពេញឲ្យគ្រប់ទៅតាមលក្ខខណ្ឌតម្រូវជាទូទៅសម្រាប់ការទទួលយក[19]។ ងាកមកមើលបញ្ហា**ទីពីរ**វិញ តុលាការ ICTY បានបកស្រាយប្រយោគ "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ" ស្របទៅតាមន័យធម្មតា។ អង្គជំនុំជម្រះសាលាដំបូងបានសំរេចលើករណីរបស់ *Milosevic* ថា៖

> "ប្រយោគ "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ" ដែលចែងនៅក្នុងវិធាន៩២*ស្ទួន* គឺជាសំដីនិយាយបែបសាមញ្ញដែលគួរតែត្រូវបានផ្ដល់ន័យទៅតាមន័យធម្មតារបស់វាថា ៖ <u>អំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ</u>។ មិនគួរពង្រីកន័យបន្ថែមក្នុងការបកស្រាយទៅតាមគំនិតស្រមើស្រម័យឡើយ។ <u>គ្មានការបញ្ជាក់និទ្ទេសអំពីអំពើនិងការប្រព្រឹត្តិ ត្រូវបានធ្វើឡើងដោយជនទាំងឡាយដែលត្រូវបានចោទប្រកាន់ថា ជាសហចារី, អ្នកនៅក្រោមបង្គាប់, ឬតាមពិត របស់ជនដទៃណាម្នាក់ទៀតនោះឡើយ</u>" បើសិនជាក្នុងវិធានមានបំណងចង់ពង្រីកន័យបន្ថែមសំដៅថា អំពើ ឬការប្រព្រឹត្តរបស់ជនដែលត្រូវបានចោទប្រកាន់ថា ជាសហចារី ឬអ្នកដែលនៅក្រោមបង្គាប់នោះ មុខជាគេចែងនៅក្នុងវិធានចែងថាដូច្នេះបាត់ទៅហើយ"[20]។(សង្កត់ន័យបន្ថែម)

១៦-ក្នុងការបរិយាយលំអិតអំពីន័យរបស់ប្រយោគនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសំរេចថា វិធាន ៩២ស្ទួន គឺមិនមានរួមបញ្ចូលនូវចម្លើយនានាជាលាយលក្ខណ៍អក្សរដែលសំដៅទៅរកការបង្ហាញសក្ខីកម្មចំពោះអំពើ ឬការប្រព្រឹត្តណាមួយរបស់ជនជាប់ចោទ ដែលខាងអយ្យការខំស្វែងរកដើម្បីបង្ហាញភ័ស្តុតាងឲ្យឃើញការពិតអំពី៖

(ក) "ថា ជនជាប់ចោទបានប្រព្រឹត្ត (ដែលថាគាត់គឺជាអ្នកដែលបានប្រព្រឹត្តដោយខ្លួនគាត់ផ្ទាល់) នូវឧក្រិដ្ឋកម្មណាមួយចំនួនក្នុងចំណោមឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់នោះដោយខ្លួនគាត់ផ្ទាល់តែម្តង ឬ

---

[19]ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Sikirica និង ជនដទៃទៀត, សំណុំរឿងលេខ IT-95-08-T, សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាដែលស្នើឲ្យយល់ព្រមទទួលយកប្រតិចារឹកមួយចំនួន អនុលោមតាមវិធាន៩២ស្ទួន, ចុះថ្ងៃទី២៣ ឧសភា ២០០១, កថាខណ្ឌទី៣។ ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Lukic, សំណុំរឿងលេខ IT-98-32/1-T, សេចក្តីសម្រេចលើញត្តិស្នើសុំរបស់រដ្ឋអាជ្ញាដែលស្នើឲ្យយល់ព្រមទទួលយកនូវភ័ស្តុតាងអនុលោមតាមវិធាន ៩២ស្ទួន, ចុះថ្ងៃទី២២សីហា២០០៨, កថាខណ្ឌទី១៥។

[20] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Milosevic, សំណុំរឿងលេខ IT-02-54-T, សេចក្តីសម្រេចលើសំណើសុំរបស់រដ្ឋអាជ្ញាដែលស្នើឲ្យយល់ព្រមទទួលយកនូវចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ អនុលោមតាមវិធាន ៩២ស្ទួន, ចុះថ្ងៃទី២១ មិនា ២០០២, កថាខណ្ឌទី២២។

(ខ) ថា គាត់បានរៀបចំផែនការ បានញុះញង់ ឬបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ឬក៏

(គ) ថា ម៉្យាងទៀត គាត់បានជួយឧបត្ថម្ភ និងជំរុញដល់ជនទាំងឡាយ ដែលជាក់ស្តែងបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងឡាយដែលនៅក្នុងការរៀបចំផែនការ ការត្រៀមរៀបចំ ឬការអនុវត្តនូវឧក្រិដ្ឋកម្មទាំងនោះ ឬក៏

(ឃ) ថាគាត់ជាថ្នាក់លើមួយរូបរបស់ពួកអ្នកដែលជាក់ស្តែងបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ ឬក៏

(ង) ថា គាត់បានដឹង និងមានមូលហេតុដែលត្រូវតែដឹងថា ឧក្រិដ្ឋកម្មទាំងនេះបំរុងនឹងប្រព្រឹត្ត ឬត្រូវបានប្រព្រឹត្តរួចហើយដោយកូនចៅក្រោមបង្គាប់ទាំងឡាយរបស់ខ្លួន ឬក៏

(ច) ថា គាត់មានការខកខានមិនបានចាត់វិធានការណ៍សមស្របផ្សេងៗដើម្បីទប់ស្កាត់អំពើទាំងនោះ ឬដើម្បីផ្តន្ទាទោសជនដែលប្រព្រឹត្តនូវអំពើទាំងនោះ”[21]។

១៧-ករណីបើសិនជា ជនជាប់ចោទណាម្នាក់ត្រូវបានចោទថា បានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម (JCE)នោះ អនុវិធាន៩២*ស្ទួន*(ក) បានហាមឃាត់មិនឲ្យទទួលយកនូវចម្លើយជាលាយលក្ខណ៍អក្សរទាំងឡាយដែលឈានទៅផ្តល់សក្ខីកម្មអំពីអំពើ ឬការប្រព្រឹត្តិណាមួយរបស់ជនជាប់ចោទ ដែលអាចឲ្យខាងអយ្យការពឹងផ្អែកលើ ដើម្បីបង្ហាញការពិតអំពី៖

(ក) “ថា គាត់បានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម” ឬ

(ខ) “ថា គាត់បានចែករំលែកជាមួយនឹងជនដែលជាក់ស្តែង ជាអ្នកប្រព្រឹត្តបទឧក្រិដ្ឋនូវចេតនាដែលតម្រូវឲ្យមានសម្រាប់ឧក្រិដ្ឋកម្មទាំងនោះ”[22]។

១៨-លើសពីនេះ ករណីប្រសិនបើ ជនជាប់ចោទណាម្នាក់ត្រូវបានចោទប្រកាន់ថា ជាអ្នកត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌដោយផ្អែកលើមូលដ្ឋាននៃអំពើផ្សេងៗរបស់ជនដទៃៗទៀត ការញែកឲ្យដាច់ពីគ្នាមួយគោងតែត្រូវបានធ្វើឡើងរវាងការដែលឈានទៅបង្ហាញសក្ខីកម្ម៖ (១)ពីអំពើ និងការប្រព្រឹត្តិរបស់ជន

[21] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Galic, កថាខណ្ឌទី១០។

[22] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Galic, កថាខណ្ឌទី១០ (ដោយរំលងចោលនូវលេខយោងជើងទំព័រ)។

ដទៃដែលប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះដែលជនជាប់ចោទត្រូវបានចោទ ថាជាអ្នកដែលត្រូវទទួលខុសត្រូវ”[អាចទទួលយកបាន] និង (២) អំពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបង្ហាញសក្ខីកម្មឲ្យឃើញពីការទទួលខុសត្រូវរបស់គាត់ចំពោះអំពើ និងការប្រព្រឹត្តរបស់ជនដទៃទាំងនោះ”[មិនអាចទទួលយកបានទេ][23]។ ស្រដៀងគ្នានេះដែរ ភ័ស្តុតាងសក្ខីកម្មជាលាយលក្ខណ៍អក្សរ ស្តីពីអំពើ និងការប្រព្រឹត្តិរបស់ជនដទៃទាំងនោះត្រូវបានលើកយកមកធ្វើជាភ័ស្តុតាង ដើម្បីបង្ហាញការពិតអំពីស្ថានភាពខាងស្មារតីរបស់ជនជាប់ចោទ (ឧទាហរណ៍ដូចជា ការដឹងថា អំពើរបស់គាត់ដូចគ្នាបេះបិទនឹងគំរូនៃការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធ) គឺអាចទទួលយកបាន[24]។

១៩-វិធាន ៩២*ស្ទួន(ខ)* តម្រូវឲ្យចម្លើយណាមួយត្រូវតែអមដោយសេចក្តីប្រកាសមួយដែលចុះហត្ថលេខាដោយសាក្សីមកជាមួយផង ដែលជាការផ្ទៀងផ្ទាត់ដើម្បីបញ្ជាក់ថា ខ្លឹមសារនៅក្នុងចម្លើយនោះ គឺជាការពិត និងត្រឹមត្រូវ។ សេចក្តីប្រកាសតោងតែមានចុះហត្ថលេខាដឹងឮជាសាក្សី ដោយមន្ត្រីដែលត្រូវបានអនុញ្ញាតណាម្នាក់ក្នុងរដ្ឋណាមួយ ឬមន្ត្រីដែលជាអធិបតីមួយរូបដែលត្រូវបានតែងតាំងដោយក្រឡាបញ្ជីនៃតុលាការ ICTY[25]។

២០- លើបញ្ហាទីបី ករណីយុត្តិសាស្ត្ររបស់តុលាការ ICTY ផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះសាលាដំបូងណាមួយគួរត្រូវបានណែនាំដោយកាតព្វកិច្ចដែលសំខាន់លើសអ្វីៗទាំងអស់ ដើម្បីធានាឲ្យការជំនុំជម្រះក្តីប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌[26] និងតម្រូវឲ្យសាក្សីចូលមកបង្ហាញខ្លួនសំរាប់ការសួរដេញដោលដោយភាគីផ្សេងទៀត បើសិនជា៖ (១) ភ័ស្តុតាងរបស់ខ្លួន ដែលសំរាប់ធ្វើជាស្នូលឲ្យករណីនៃការចោទប្រកាន់[27] (២) មានភាពជិតស្និទ្ធគ្នាបំផុតរវាងជនដែលអំពើ និងការប្រព្រឹត្តិរបស់ខ្លួនដែលសាក្សីបាន

---

[23] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Karadzic, សំណុំរឿងលេខ IT-95-5/18-PT, សេចក្តីសម្រេចលើញត្តិស្នើសុំលើកទី៣ របស់រដ្ឋអាជ្ញាដែលស្នើឲ្យយល់ព្រមទទួលយកនូវចម្លើយ និងប្រតិចារឹកនៃភ័ស្តុតាងមួយចំនួន ជាជំនួសឲ្យចម្លើយ*ដោយផ្ទាល់មាត់* អនុលោមតាមវិធាន ៩២*ស្ទួន* (សាក្សីសម្រាប់ឲ្យសាលាក្រុង Sarajevo), ចុះថ្ងៃទី១៥ តុលា ២០០៩, កថាខណ្ឌទី៥។

[24] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Galic, កថាខណ្ឌទី១១។

[25] វិធាន៩២*ស្ទួន*(ខ) នៃតុលាការ ICTY។

[26] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Sikirica និងជនដទៃទៀត, សំណុំរឿងលេខ IT-95-08-T, សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាដែលស្នើឲ្យយល់ព្រមទទួលយកប្រតិចារឹកមួយចំនួន អនុលោមតាមវិធាន៩២*ស្ទួន*, ចុះថ្ងៃទី២៣ ឧសភា ២០០១, កថាខណ្ឌទី៤។

[27] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Blagojevic និង Jokic, សំណុំរឿងលេខ IT-02-60-T, សេចក្តីសម្រេចលើកទី១លើញត្តិស្នើសុំរបស់រដ្ឋអាជ្ញា ដែលស្នើឲ្យយល់ព្រមទទួលយកនូវចម្លើយសាក្សី និងសក្ខីកម្មពីមុនៗ អនុលោមតាមវិធាន៩២*ស្ទួន*, ចុះថ្ងៃទី១២ មិថុនា ២០០៣,

រៀបរាប់ ហើយនិងជនជាប់ចោទ (ឧទាហរណ៍ដូចជា ភ័ស្តុតាងដែលទាក់ទងនឹងការប្រព្រឹត្តិរបស់អ្នកក្រោមបង្គាប់ផ្ទាល់ណាម្នាក់របស់ជនជាប់ចោទ)[28] (៣) ភ័ស្តុតាងរបស់សាក្សីដែលទាក់ទងនឹង" បញ្ហាផ្ទាល់ និងសំខាន់រវាងភាគីនានា ដែលផ្ទុយគ្នានឹងបញ្ហាពាក់ព័ន្ធសេរីៗខាងក្រៅ ឬបន្ទាប់បន្សំ"[29]។

២១- វិធាន ៩៤*ស្ទួន៤* នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាង អនុញ្ញាតឲ្យទទួលយកនូវចម្លើយរបស់សាក្សីនានាដែលបានទទួលមរណៈភាព ដែលមិនអាចតាមរកឃើញ ឬម៉្យាងទៀត មិនអាចមានលទ្ធភាពមកផ្តល់សក្ខីកម្មបាន។ ភ័ស្តុតាងនេះអាចទាក់ទងទៅនឹងសក្ខីកម្មស្តីពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទណាម្នាក់[30]។

*អំពីការអនុវត្តគោលការណ៍ទាំងនេះដោយតុលាការអន្តរជាតិនានា*

២២- ការអនុវត្តវិធាន៩២*ស្ទួន* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានយល់ព្រមទទួលយកជាច្រើនលើកច្រើនសារនូវចម្លើយរបស់សាក្សី និងប្រតិចារឹកនានាដែលមកពីអង្គសវនាការជំនុំជម្រះក្តីដទៃៗទៀត ដោយមិនមានការតម្រូវឲ្យសាក្សីចូលមកបង្ហាញខ្លួន ដើម្បីឲ្យភាគីផ្សេងទៀតសួរដេញដោលនោះឡើយ។ តុលាការទាំងនោះតែងតែធ្វើយ៉ាងដូច្នេះ ក្នុងករណីដែលខ្លួនរកឃើញថា កំណត់ហេតុជាលាយលក្ខណ៍អក្សរទាំងនេះ មិនមានការទាក់ទងគ្នានឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់

---

កថាខណ្ឌទី២៨។ ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Perisic, សំណុំរឿងលេខ IT-04-81-T, សេចក្តីសម្រេចលើញត្តិស្នើសុំរបស់រដ្ឋអាជ្ញាដែលស្នើឲ្យយល់ព្រមទទួលយកនូវភ័ស្តុតាងអនុលោមតាមវិធាន ៩២ស្ទួន, ចុះថ្ងៃទី២ តុលា ២០០៨, កថាខណ្ឌទី១៤។

[28] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Galic, កថាខណ្ឌទី១៦។ ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Blagojevic និង Jokic, សំណុំរឿងលេខ IT-02-60-T, សេចក្តីសម្រេចលើកទី១លើញត្តិស្នើសុំរបស់រដ្ឋអាជ្ញា ដែលស្នើឲ្យយល់ព្រមទទួលយកនូវចម្លើយសាក្សី និងសក្ខីកម្មពីមុនៗ អនុលោមតាមវិធាន៩២*ស្ទួន*, ចុះថ្ងៃទី១២ មិថុនា ២០០៣, កថាខណ្ឌទី១២,១៩។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Bradnin និង Talic,* សំណុំរឿងលេខ IT-99-36-T, ចុះថ្ងៃទី២៣ ឧសភា ២០០២, អត្ថបទជាសាធារណៈនៃសេចក្តីសម្រេចជាការសម្ងាត់លើសំណើសុំការយល់ព្រមទទួលយកនូវចម្លើយអនុលោមតាមវិធាន ៩២*ស្ទួន,* ចុះថ្ងៃទី១ ឧសភា ២០០២, កថាខណ្ឌទី១៤។ ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Popovic និងជនដទៃទៀត, សំណុំរឿងលេខ IT-05-88-T, សេចក្តីសម្រេចលើសំណើសុំជាសម្ងាត់ឲ្យយល់ព្រមទទួលយកនូវភ័ស្តុតាងជាលាយលក្សណ៍អក្សរជាជំនួសឲ្យការផ្តល់សក្ខីកម្ម*ដោយផ្ទាល់មាត់*អនុលោមតាមវិធាន ៩២*ស្ទួន,* ចុះថ្ងៃទី១២ កញ្ញា ២០០៦, កថាខណ្ឌទី១៣។

[29] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Milosevic, សំណុំរឿងលេខ IT-02-54-T, សេចក្តីសម្រេចលើសំណើសុំរបស់រដ្ឋអាជ្ញាដែលស្នើឲ្យយល់ព្រមទទួលយកនូវចម្លើយសាក្សីជាលាយក្សណ៍អក្សរ អនុលោមតាមវិធាន ៩២ស្ទួន, ចុះថ្ងៃទី២១ មិនា ២០០២, កថាខណ្ឌទី២៤។

[30] បើសិនជាចម្លើយមិនទាក់ទងគ្នានឹងអំពើនិងការប្រព្រឹត្តរបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ អាចជាកត្តាមួយដែលប្រឆាំងនឹងការទទួលយក។ វិធាន៩២*ស្ទួន*បួន(ខ)។

ចោទទេ ប៉ុន្តែក្នុងនោះមានភ័ស្តុតាងអំពីទីកន្លែងឧក្រិដ្ឋកម្មដែលមានលក្ខណៈត្រួតគ្នាមួយដែលជាប់ទាក់ទងគ្នានឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះនានា ឬដែលមាននៅក្នុងព័ត៌មានពីប្រវត្តិដើមដែលពាក់ព័ន្ធ។

(ក) នៅក្នុង*ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Karadzic* អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមទទួលយកចម្លើយសាក្សីនានា និងប្រតិចារឹកមួយ នៅមុនពេលសវនាការដែលបានលើកយកមកពិភាក្សា នៅក្នុងចំណោមបញ្ហាផ្សេងៗទៀតជាច្រើន លើបញ្ហា៖ ការដណ្តើមកាន់កាប់ទីក្រុង ការបណ្តេញចេញ និងការធ្វើបាបប្រជាជនបូស្នីដែលកាន់សាសនាឥស្លាម។ ការនិយាយរឿងរ៉ាវផ្ទាល់ខ្លួនអំពីការជាប់ពន្ធនាគារ។ ការប្រើប្រាស់មនុស្សធ្វើជាខែល។ និងការបំផ្លិចបំផ្លាញភូមិនានា។ ទោះបីជានៅក្នុងភ័ស្តុតាងមានរាយឈ្មោះសមាជិកនៃសហកម្មឧក្រិដ្ឋកម្មរួមដែលមានសក្តានុពលនានាយ៉ាងណាក្តីក៏ភ័ស្តុតាងនេះមិនឈានទៅដល់ធ្វើជាសក្ខីកម្មអំពីអំពើ ឬការប្រព្រឹត្តិណាមួយដែលបង្ហាញឲ្យឃើញការពិតថា ជនជាប់ចោទបានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនោះឡើយ។ មិនមានអ្វីគ្រប់គ្រាន់ ដើម្បីភ្ជាប់ឈ្មោះណាមួយក្នុងចំណោមឈ្មោះទាំងនោះទៅនឹងសាក្សី ដើម្បីអាចឲ្យផ្តល់ការអនុញ្ញាតឲ្យពួកគេត្រូវចូលមកបង្ហាញខ្លួន ដើម្បីឲ្យភាគីម្ខាងទៀតធ្វើការសួរដេញដោលបានឡើយ[31]។

(ខ) នៅក្នុង*ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Blagojevic និង Jokic* អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមទទួលយកកំណត់ហេតុនៃចម្លើយសាក្សីនានាជាលាយលក្ខណ៍អក្សរ របស់សាក្សីចំនួន១៦នាក់។ ក្នុងចម្លើយសាក្សីទាំងនោះមាន ភ័ស្តុតាងអំពីទីកន្លែងនៃឧក្រិដ្ឋកម្ម ហើយមិនបានបញ្ជាក់អំពីជនជាប់ចោទ ឬអំពីការចូលរួមរបស់ពួកគេនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមណាមួយឡើយ។ ភ័ស្តុតាងទាំងនេះក៏មិនទាក់ទងនឹងចារីនានាដែលមានការជិតស្និទ្ធខ្លាំងជាមួយជនជាប់ចោទដែរ ហើយដែលម្យ៉ាងទៀតមានលក្ខណៈជាស្នូលយ៉ាងខ្លាំងដែលតម្រូវថាត្រូវឲ្យមកផ្តល់សក្ខីកម្ម*ដោយផ្ទាល់មាត់*នោះដែរ។ ភ័ស្តុតាង

[31] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Karadzic, សំណុំរឿងលេខ IT-95-5/18-PT, សេចក្តីសម្រេចលើញត្តិស្នើសុំលើកទី៣ របស់រដ្ឋអាជ្ញាដែលស្នើឲ្យយល់ព្រមទទួលយកនូវចម្លើយ និងប្រតិចារឹកនៃភ័ស្តុតាងមួយចំនួន ជាជំនួសឲ្យចម្លើយ *ដោយផ្ទាល់មាត់* អនុលោមតាមវិធាន ៩២*ស្ទួន* (សាក្សីសម្រាប់ឲ្យទីក្រុង Sarajevo), ចុះថ្ងៃទី១៥ តុលា ២០០៩, កថាខណ្ឌទី១៣-២៧។

ក៏មានភាពត្រូតលើគ្នាដែរ ដោយសារសាក្សីដទៃទៀតត្រូវមកផ្តល់សក្ខីកម្មអំពីអង្គហេតុដែលស្រដៀងគ្នានេះនៅក្នុងពេលសវនាការ[32]។

(គ) នៅក្នុង*ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Milosevic អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមទទួលយកចម្លើយសាក្សីនានាដែលទាក់ទងនឹងការវាយប្រហារដោយការបាញ់គ្រាប់ផ្លោងដែលធ្វើឡើង ដោយកងកម្លាំងដែលស្ថិតនៅក្រោមបញ្ជារបស់ជនជាប់ចោទ។ អង្គជំនុំជម្រះបានបង្គាប់ឲ្យលុបចេញនូវផ្នែកខ្លះពីក្នុងចម្លើយសាក្សីទាំងនោះ ដែលមានភ័ស្តុតាងជាការផ្តល់យោបល់ និងភ័ស្តុតាងស្តីពីវត្តមាននៃកងកម្លាំងយោធានៅកន្លែងដែលជាមុខសញ្ញា ដែលជាបញ្ហាដ៏ធ្ងន់ធ្ងរនៅក្នុងករណីរឿក្តីនេះ[33]។

(ឃ) នៅក្នុង*ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Perisic អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមទទួលយកកំណត់ហេតុនៃចម្លើយសាក្សីនានា (និងវត្ថុតាងនានាដែលភ្ជាប់ជាមួយ) ដែលនៅក្នុងនោះមានភ័ស្តុតាងស្តីពីការវាយប្រហារដោយការបាញ់គ្រាប់ផ្លោង និងឯកសារពេទ្យដែលនៅមន្ទីរពេទ្យដែលបានផ្តល់ការព្យាបាលដល់ជនរងគ្រោះ ដោយសារការវាយប្រហារទាំងនោះ។ ចំណែកឯមេធាវីការពារក្តីមិនបានធ្វើការការជំទាស់ចំពោះការយល់ព្រមទទួលយកនូវចម្លើយទាំងនេះទេ អង្គជំនុំជម្រះបានធ្វើការវាយតម្លៃចំពោះការអនុវត្តតាមវិធានរបស់ពួកគេ។ ជាសំខាន់ គឺមានចម្លើយចំនួនពីរនៃចម្លើយទាំងនោះមិនត្រូវបានផ្តល់ទៅឲ្យពួកអ្នកស៊ើបអង្កេតនៃតុលាការ ICTY នោះទេ តែបានផ្តល់ទៅឲ្យអាជ្ញាធរផ្សេងទៀតនៅបូស្នី អ៊ែរហ្សេហ្គោវីណាទៅវិញ[34]។

---

[32] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Blagojevic និង Jokic, សំណុំរឿងលេខ IT-02-60-T, សេចក្តីសម្រេចលើកទី១ លើញត្តិស្នើសុំរបស់រដ្ឋអាជ្ញា ដែលស្នើឲ្យយល់ព្រមទទួលយកនូវចម្លើយសាក្សី និងសក្ខីកម្មពីមុនៗ អនុលោមតាមវិធាន៩២*ស្ទួន*, ចុះថ្ងៃទី១២ មិថុនា ២០០៣, កថាខណ្ឌទី១៧-២០,២២, និង២៨។

[33] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Milosevic, សំណុំរឿងលេខ IT-98-29/1-T, សេចក្តីសម្រេចលើសំណើសុំរបស់រដ្ឋអាជ្ញាដែលស្នើឲ្យយល់ព្រមទទួលយកនូវចម្លើយសាក្សី អនុលោមតាមវិធាន ៩២ស្ទួន, ចុះថ្ងៃទី៣ មេសា ២០០៧។

[34] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* ***Perisic,*** សំណុំរឿងលេខ IT-04-81-T, សេចក្តីសម្រេចលើញត្តិស្នើសុំរបស់រដ្ឋអាជ្ញា ដែលស្នើឲ្យយល់ព្រមទទួលយកនូវភ័ស្តុតាង អនុលោមតាមវិធាន៩២*ស្ទួន*, ចុះថ្ងៃទី២ តុលា ២០០៨, កថាខណ្ឌទី២០-៣៣។

(ង) នៅក្នុង*ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Nalatelic* អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមទទួលយកប្រតិចារឹក និងវត្ថុតាងទាំងឡាយដែលមកពីសវនាការជំនុំជម្រះក្តីកាលពីលើកមុនៗដែលសំរេចថា ភ័ស្តុតាងនេះក្លាយទៅជាសក្ខីកម្មអំពីធាតុផ្សំ *ទាំងអស់ជារួម*នៃបទល្មើស ដូចជាអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិណាមួយ និងលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធនៃការវាយប្រហារ[35]។

(ច) នៅក្នុង*ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Bradnin និង Talic* អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរនានា ដែលក្នុងនោះមានភ័ស្តុតាងដែលមានលក្ខណៈត្រួតលើគ្នា ព្រោះសាក្សីនានាដែលត្រូវធ្វើសក្ខីកម្ម *ដោយផ្ទាល់មាត់នោះ* គឺត្រូវផ្តល់សក្ខីកម្មលើអង្គហេតុដូចគ្នាដដែល។ មួយវិញទៀត អង្គជំនុំជម្រះនេះបានអនុញ្ញាតឲ្យបដិបក្សសួរដេញដោលសាក្សីទាំងនោះ ដែលនៅក្នុងចម្លើយរបស់ពួកគេមានភ័ស្តុតាងស្តីពីការប្រព្រឹត្តិរបស់ពួកទាហាន ដែលស្ថិតនៅក្រោមបញ្ជារបស់របស់ជនជាប់ចោទ ឬដែលមានទីតាំងស្ថិតនៅក្រោមសមត្ថកិច្ចរបស់គាត់[36]។

(ឆ) នៅក្នុង*ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Sikirika* អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមទទួលយកប្រតិចារឹកនៃសក្ខីកម្មសាក្សីចំនួនពីររូបដែលភ័ស្តុតាងរបស់ពួកគេគឺជាប្រវត្តិដើមដែលមានសារប្រយោជន៍ ឬដែលមិនទាក់ទងគ្នានឹងបញ្ហាជាស្នូលនៃករណីរឿងនេះ។ ម្យ៉ាងទៀត អង្គជំនុំជម្រះតម្រូវឲ្យធ្វើការសួរដេញដោលសាក្សីនានារបស់ភាគីម្ខាងទៀតដែលភ័ស្តុតាងរបស់គេជាប់ទាក់ទងទៅនឹងបញ្ហាសំខាន់ៗ នៅក្នុងរឿងក្តីនេះ ដូចជាសក្ខីកម្មអំពីបទប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាប់ចោទជាដើម[37]។

---

[35] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Naletilic, សំណុំរឿងលេខ IT-98-34-PT, សេចក្តីសម្រេចស្តីពីសេចក្តីជូនដំណឹងរបស់រដ្ឋអាជ្ញាស្តីពីការមានបំណងចង់ផ្តល់ជូននូវប្រតិចារឹកមួយចំនួន អនុលោមតាមវិធាន ៩២ស្ទួន (ឃ ), ចុះថ្ងៃទី៩ កក្កដា ២០០១, កថាខណ្ឌទី៧-១២។

[36] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Bradnin និង Talic,* សំណុំរឿងលេខ IT-99-36-T, អត្ថបទជាសាធារណៈនៃសេចក្តីសម្រេចជាការសម្ងាត់លើសំណើសុំការយល់ព្រមទទួលយកនូវចម្លើយអនុលោមតាមវិធាន ៩២*ស្ទួន,* ចុះថ្ងៃទី១ ឧសភា ២០០២, ចុះថ្ងៃទី២៣ ឧសភា ២០០២ កថាខណ្ឌទី២០,២៣- ២៥, និង៣០។

[37] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Sikirica និងជនដទៃទៀត, សំណុំរឿងលេខ IT-95-08-T, សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាដែលស្នើឲ្យយល់ព្រមទទួលយកប្រតិចារឹកមួយចំនួន អនុលោមតាមវិធាន៩២*ស្ទួន*, ចុះថ្ងៃទី២៣ ឧសភា ២០០១។

២៣- សហព្រះរាជអាជ្ញាកត់សំគាល់ឃើញថា នៅក្នុង*ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Prlic,* មេធាវីការពារក្តីអន្តរជាតិរបស់ អៀង សារី បានដាក់ពាក្យបានដោយជោគជ័យ ក្នុងការស្នើសុំឱ្យដាក់បញ្ចូលជាភស្តុតាងនូវកំណត់ហេតុនៃចម្លើយជាលាយលក្សណ៍អក្សរចំនួន៥។ ក្នុងការដែលច្រានចោលនូវការបដិសេធរបស់អយ្យការនេះ គឺអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ចម្លើយនានាគួរតែបានយល់ព្រមទទួលយក ដោយមិនចាំបាច់មានការសួរដេញដោលពីភាគីម្ខាងទៀតឡើយ។ ចម្លើយទាំងនេះ មិនទាក់ទងនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ ហើយការទទួលយកនូវចម្លើយទាំងនេះ គឺនាំឱ្យមានការធានាឲ្យប្រាកដថាដំណើរការនីតិវិធីមានប្រសិទ្ធភាព និងមានភាពឆាប់រហ័ស[38]។ ក្រៅពីនេះ មេធាវីការពារក្តីអន្តរជាតិរបស់ អៀង សារី បានព្រមព្រៀងនៅចំពោះមុខអង្គជំនុំជម្រះថា កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីទទួលយកបាន ហើយយល់ព្រមប្រកបដោយប្រសិទ្ធភាពនូវគោលការណ៍ ដែលមានចែងនៅក្នុងសេចក្តីសន្និដ្ឋាននេះ[39]។

២៤- នៅក្នុងវិធានស្តីនីតិវិធី និងភស្តុតាងរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន មានបញ្ញត្តិស្រដៀងគ្នានឹងវិធាន៩២*ស្ទួន* របស់តុលាការ ICTYដែរ[40] ហើយតុលាការនេះបានធ្វើការកត់សំគាល់ចំពោះយុត្តិសាស្ត្រដែលពាក់ព័ន្ធរបស់តុលាការ ICTY នេះ ដោយបានយល់ព្រមតាមនេះ[41]។ ក្នុងការ

[38] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Prlic , សំណុំរឿងលេខ IT-04-74-T, សេចក្តីសម្រេចលើញត្តិស្នើសុំរបស់មេធាវីការពារក្តីរបស់ Prlic សុំការយល់ព្រមទទួលយកនូវចម្លើយជាលាយលក្ខណ៍អក្សរអនុលោមតាមវិធាន ៩២*ស្ទួន,* ចុះថ្ងៃទី២៥ វិច្ឆិកា ២០០៨, កថាខណ្ឌទី១២, ១៣ និង១៦។

[39] សេចក្តីថ្លែងរបស់លោកមេធាវី Michael Karnavas អង្គប្រជុំរៀបចំសវនាការ ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១១ E1/2.1 ទំព័រទី៨៩ ដល់៩០ "ខ្ញុំព្រមព្រៀងជាមួយ លោក Smith ចំពោះកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី។ ការអនុវត្តនេះ គឺថាកំណត់ហេតុមួយចំនួន កំណត់ហេតុស្តាប់ចម្លើយសាក្សីអាចត្រូវក្នុងកាលៈទេសៈខ្លះ នៅពេលណាដែលកំណត់ហេតុនោះមិនបង្ហាញពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ។ ការទទួលខុសត្រូវរបស់ភាគីដែលប្រឹងប្រែងបង្ហាញកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ដើម្បីបង្ហាញថាវាមិនចិតនៅក្នុងរឿងក្តីនោះ ហើយភាគី និងភាគីជំទាស់ គឺមានកាលានុវត្តភាពជំទាស់បាន។ ជាឧទាហរណ៍ ប្រសិនបើអ្នកចោទប្រកាន់ ការចោទប្រកាន់នោះ គឺសហកម្មឧក្រិដ្ឋកម្មរួម នោះកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីមួយចំនួនអាចប៉ះពាល់ដល់ទស្សនៈនៃសហកម្មឧក្រិដ្ឋកម្មរួមក្នុងរឿងក្តីនេះ ដែលអាចតម្រូវ ឬមិនតម្រូវឱ្យសាក្សី ចូលមកបង្ហាញខ្លួន..."

[40] អនុវិធាន៩២ស្ទួន(ក) នៃវិធានស្តីពីនីតិវិធីនិងភស្តុតាងនៃតុលាការពិសេសសំរាប់ប្រទេសសៀរ៉ាឡេអូនដែលចែងថា៖ "ជាបន្ថែមពីលើវិធាន ៩២*ស្ទួនបួន,* អង្គជំនុំជម្រះអាច ទទួលយកជាភស្តុតាងមួយផ្នែកឬទាំងមូល ជាជំនួសឱ្យសក្ខីកម្មដោយផ្ទាល់មាត់បាន នៃព័ត៌មានដែលរួមទាំងចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារឹកទាំងឡាយណាដែលមិនមែនជាសក្ខីកម្មអំពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ។"

[41] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Norman និងជនដទៃទៀត, សំណុំរឿងលេខ SCSL-04-14-T, សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាដែលសុំឱ្យយល់ព្រមទទួលយកជាភស្តុតាងនូវឯកសារខ្លះៗអនុលោមតាមវិធាន *៩២ស្ទួន* និង៨៩.គ, ចុះថ្ងៃទី១៩ កក្កដា ២០០៥, ត្រង់ទំព័រ៤។

យកមកប្រើនូវវិធានទាំងនេះ តុលាការពិសេសនេះបានយល់ព្រមទទួលយកនូវចម្លើយសាក្សីនៃសាក្សីទាំងឡាយដែលមិនអាចចូលមកបាន ដោយដកចេញនូវផ្នែកខ្លះៗនៅក្នុងចម្លើយទាំងនោះ ដែលជាមតិផ្សេងៗ ឬដែលទាក់ទងទៅនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[42]។

២៥- ការយល់ព្រមទទួលយកនូវភស្តុតាងជាលាយលក្ខណ៍អក្សរជាជំនួសឲ្យសក្ខីកម្មដោយផ្ទាល់មាត់ គឺមានលក្ខណៈស្របទៅតាមការអនុម័តយករបស់តុលាការអន្តរជាតិនានានូវវិធានបត់បែនដែលទាក់ទងទៅនឹងភាពអាចទទួលយកបាននៃភស្តុតាង។ នៅក្នុងយុត្តិសាស្ត្រអន្តរជាតិ សេចក្តីសម្រេចទាំងឡាយស្តីពីភាពអាចទទួលយកបាននៃភស្តុតាង គឺស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង[43]។ ភស្តុតាងអាចឲ្យទទួលយកបាន បើសិនជាមានការជាប់ទាក់ទង និងមានតម្លៃជាភវនីយភាព។ ទម្ងន់ដែលត្រូវផ្តល់ឲ្យត្រូវបានកំណត់សំរេចនៅក្នុងពេលធ្វើការវាយតម្លៃទៅលើតម្លៃជាភវនីយភាពនៃភស្តុតាងទាំងមូល[44]។

២៦- ការពិចារណាដ៏មានសារសំខាន់មួយបន្ថែមទៀតដែលគាំទ្រចំពោះការទទួលយកភស្តុតាង ក្នុងទម្រង់ជាចម្លើយជាលាយលក្ខណ៍អក្សរ គឺការចាំបាច់ត្រូវបើកធ្វើសវនាការឲ្យបានឆាប់រហ័សក្នុងលក្ខណៈ

---

[42] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Norman និងជនដទៃទៀត, សំណុំរឿងលេខ SCSL-04-14-T, សេចក្តីសម្រេចលើសំណើរបស់ Fofana ដែលសុំឲ្យយល់ព្រមទទួលយកនូវភស្តុតាងអនុលោមតាមវិធាន ៩២ស្ទួន, ចុះថ្ងៃទី៩ តុលា ២០០៦, ត្រង់កថាខណ្ឌទី២២-២៧។

[43] *សូមអាន ឧទាហរណ៍ដូចជា* ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Arsene Shalom Ntahobali និង Pauline Nyiramasuhuko, សំណុំរឿងលេខ ICTR -97-21-AR73, សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ លើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ Arsene Shalom Ntahobali ដែលប្រឆាំងនឹងសេចក្តីសម្រេចលើញត្តិដោយផ្ទាល់មាត់របស់ Kanyabashi ដែលស្នើសុំឲ្យសួរដេញដោល Ntahobali ដោយប្រើប្រាស់នូវចម្លើយរបស់ Ntahobali ដែលបានផ្តល់ទៅឲ្យ ពួកអ្នកស៊ើបអង្កេតរបស់អយ្យការកាលពីក្នុងខែតុលា ឆ្នាំ១៩៩៧, ចុះថ្ងៃទី២៧ តុលា ២០០៦, កថាខណ្ឌទី១០។

[44] វិធាន៨៩(គ)នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការ ICTY។ ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Norman និងជនដទៃទៀត, សំណុំរឿងលេខ SCSL-04-14-AR65, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Fofana -ដែលប្រឆាំងនឹងសេចក្តីសម្រេចដែលបដិសេធមិនយល់ព្រមឲ្យបង់ប្រាក់ធានាឲ្យនៅក្រៅឃុំ, ចុះថ្ងៃទី១១ មីនា ២០០៥, ត្រង់កថាខណ្ឌទី២២-២៤។ ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Norman និងជនដទៃទៀត, សំណុំរឿងលេខ SCSL-04-14-T, សេចក្តីសម្រេចលើសំណើរបស់ Norman ដែលសុំឲ្យយល់ព្រមទទួលយកនូវឯកសារជាជំនួសឲ្យការផ្តល់សក្ខីកម្មរបស់ Abdul-one Mohammed អនុលោមតាមវិធាន ៨៩.គ និង*៩២ស្ទួន*, ចុះថ្ងៃទី១៥ កញ្ញា ២០០៦, ត្រង់ទំព័រ៤ ។ ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Issa Hassan Sesay និងជនដទៃទៀត, សំណុំរឿងលេខ SCSL-04-15-T, សេចក្តីសម្រេចលើញត្តិស្នើសុំរួមរបស់មេធាវីការពារក្តីដែលស្នើសុំឲ្យអនុវត្តស្របទៅតាមការអនុវត្តនីតិវិធីក្នុងការស្រង់យកចម្លើយសាក្សីនានា, ចុះថ្ងៃទី២៦ តុលា ២០០៥, កថាខណ្ឌទី៣៨។

សមហេតុសមផល។ ដូចដែលលោកចៅក្រមឈ្មោះ Kwon ជាចៅក្រមដែលធ្លាប់មានបទពិសោធន៍ អនុវត្តន៍នៃប្រព័ន្ធច្បាប់ស៊ីវិលមួយរូប បានបញ្ជាក់នៅក្នុងសេចក្តីប្រកាសរបស់លោកនៅក្នុងករណីរឿង របស់ Milosevic ថា៖

> “ ដោយមានវិធីសាស្ត្របត់បែនជាងមុនក្នុងការទទួលយកនូវចម្លើយសាក្សីនានា ដោយសមត្ថភាពរបស់ អង្គជំនុំជម្រះសាលាដំបូងក្នុងការចាត់ចែងគ្រប់គ្រងសវនាការនានាដែលមានទំហំខ្នាតធំ...បានដោយ ប្រសិទ្ធភាពជាងមុន និងធ្វើឲ្យបានកាន់តែល្អប្រសើរឡើងនូវ...[]អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវ បានជួយ ដោយសារតែការដែលអាចមានលទ្ធភាពរកឃើញដោយងាយស្រួលជាងមុន៖ សាក្សីណាម្នាក់ នៅក្នុងពេលសវនាការអាចនឹងមិនផ្តល់នូវភ័ស្តុតាងរបស់ខ្លួនបានពេញលេញនោះទេ ដោយសារ មូលហេតុមកពីពេលវេលាមានកំរិត ដោយការអៀនខ្មាស់ ឬដោយសារហេតុផលមួយចំនួនផ្សេង ទៀត...រីឯហានិភ័យតែងតែមានជានិច្ចកាលដែលថា ចម្លើយណាមួយអាចនឹងមិនបានរៀបរាប់រឿងរ៉ាង អំពីព្រឹត្តិការណ៍ពោរពេញដោយការពិតនោះទេ ឬមួយក៏មានការពិតតែដោយអន្លើៗប៉ុណ្ណោះ ការណ៍នេះ មិនគួរច្រានចោលជាមុនមិនទទួលយកនូវចម្លើយសាក្សីជាទូទៅ ដើម្បីធ្វើជាភ័ស្តុតាងនោះឡើយ។ ចៅក្រមអាជីពទាំងឡាយតោងតែមានការប្រុងប្រយ័ត្នចំពោះគ្រោះថ្នាក់បែបនេះ និងត្រូវមានសមត្ថភាព ដើម្បីកត់សំគាល់ពីភាពមិនចុះសម្រុងគ្នាដោយអន្លើៗរវាងចម្លើយជាលាយលក្ខណ៍អក្សរ និងចម្លើយ ផ្ទាល់មាត់ ហើយត្រូវកំណត់សំរេចថា តើគួរផ្តល់ទម្ងន់ត្រឹមណាចំពោះភ័ស្តុតាងនោះ....[]នេះ គឺជាការ អនុវត្តជាទូទៅជារួមនៅក្នុងការយល់ព្រមទទួលយកនូវភ័ស្តុតាងនានាក្នុងប្រព័ន្ធច្បាប់ស៊ីវិល”[45]។

២៧- ជាចុងក្រោយ វាជាការពាក់ព័ន្ធដែរដែលត្រូវកត់សំគាល់ថា សូម្បីនៅមុនការអនុម័តវិធាន៩២ស្ទួន តុលាការ ICTY បានប្រើប្រាស់នូវឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីទទួលយកកំណត់ហេតុជាលាយលក្ខណ៍ អក្សរជាភ័ស្តុតាងដែរ។ នៅលើបណ្តឹងឧទ្ធរណ៍មួយប្រឆាំងនឹងសេចក្តីសម្រេច អំពីការទទួលយក កំណត់ហេតុជាលាយលក្ខណ៍អក្សរនានា អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា៖

> “គោលបំណងរបស់វិធាន គឺដើម្បីលើកកម្ពស់សវនាការដ៏ត្រឹមត្រូវយុត្តិធម៌ និងឆាប់រហ័ស ហើយអង្គជំនុំ ជម្រះសាលាដំបូងត្រូវតែមានភាពបត់បែន ដើម្បីសម្រេចបានគោលដៅនេះ...។ ក្នុងកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិពិចារណាពីដំណាក់កាលនៃសវនាការ និងរយៈពេលដែលជនជាប់ចោទ

---

[45] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Milosevic, សំណុំរឿងលេខ IT-02-54-T, សេចក្តីសម្រេចលើសំណើសុំរបស់រដ្ឋអាជ្ញាដែលស្នើឲ្យ យល់ព្រមទទួលយកនូវចម្លើយសាក្សីជាលាយក្សណ៍អក្សរ អនុលោមតាមវិធាន ៩២ស្ទួន, ចុះថ្ងៃទី២១ មិនា ២០០២, សេចក្តីប្រកាសរបស់ លោកចៅក្រម O-Gon Kwon, កថាខណ្ឌទី៣។

បានស្ថិតនៅក្នុងការឃុំឃាំង និងការរកឃើញរបស់ខ្លួនថា សាក្សីមិនអាចឱ្យគេរកបានភ្លាមៗឡើយ នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីទទួលយកភ័ស្តុតាង”[46]។

## ***តុលាការអន្តរជាតិ***

២៨- យុទ្ធវិធីខុសគ្នាមួយត្រូវបានទទួលយកនៅក្នុងវិធាននៃភ័ស្តុតាង និងនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ កំណត់ហេតុរបស់សាក្សីមុនពេលសវនាការ គឺអាចទទួលយកបានដោយពុំចាំបាច់មានវត្តមានរបស់សាក្សីនៅពេលសវនាការឡើយ វៀរលែងតែអយ្យការ និងមេធាវីការពារក្តីមានឱកាសពិនិត្យសាក្សីនោះ ក្នុងអម្លុងពេលនៃការធ្វើកំណត់ត្រាកំណត់ហេតុនោះ[47]។ ក្នុងករណី *Lubanga* អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សំគាល់ទៅលើវិធាននេះ ប៉ុន្តែក៏បានទទួលស្គាល់ផងដែរថា មាត្រា៦៨(២) នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម អនុញ្ញាតឱ្យតុលាការ “អនុវត្តចំពោះផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីដោយសម្ងាត់ ឬអនុញ្ញាតឱ្យមានការបង្ហាញភ័ស្តុតាងតាមអេឡិចត្រូនិច <u>ឬតាមមធ្យោបាយពិសេសផ្សេងទៀត</u>”។ ហេតុដូច្នេះ មាត្រា៦៨(២)នេះ “ផ្តល់លទ្ធភាពឱ្យតុលាការផ្តល់ការការពារដល់ជនរងគ្រោះ សាក្សី ឬជនជាប់ចោទ នៅពេលណាចាំបាច់ដើម្បីប្រើប្រាស់នូវ “មធ្យោបាយពិសេសណាមួយ” ដែលសមស្រប ដែលនឹងរាប់បញ្ចូលទាំងការអានមួយផ្នែក ឬទាំងអស់នៃកំណត់ហេតុរបស់សាក្សីក្នុងតុលាការដោយចំហរ ឬជាឯកជន ដរាបណាជំហានទាំងអស់នេះ មិនធ្វើឱ្យខូចដល់ភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី”[48]។

២៩- វិធានរបស់ ICC គឺមានការពាក់ព័ន្ធតិចជាងក្នុងករណីបរិបទនេះ ដោយហេតុថា វិធានទាំងនោះមានការដាក់កំហិតច្បាស់លាស់ទៅលើការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរ ដែលនេះជាយុទ្ធវិធីមួយដែលត្រូវបានយកតាមទេនៅ អ.វ.ត.ក នេះ។ ការកំហិតដូច្នេះនឹងផ្ទុយពីស្មារតីនៃនីតិវិធីច្បាប់រដ្ឋប្បវេណីជាធរមាននៅអ.វ.ត.ក ដែលក្នុងនោះភ័ស្តុតាងត្រូវបានគេប្រមូលដោយមន្ត្រីតុលាការមិនលំអៀង និងបន្ទាប់មកត្រូវបានគេបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង។ ដូចបានធ្វើការកត់សំគាល់ខាងក្រោមនេះ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក មិនបានអនុវត្តតាមយុទ្ធវិធីរបស់ ICC ទេ។

---

[46] រដ្ឋអាជ្ញា ទល់នឹង Aleksovski, IT-95-14/1-AR73, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាស្តីពីភាពអាចទទួលយកបាននៃភ័ស្តុតាង, ១៦ កុម្ភៈ ១៩៩៩, កថាខ័ណ្ឌទី១៩ ។

[47] វិធាន៦៨(ក) នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាង នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

[48] រដ្ឋអាជ្ញា ទល់នឹង Lubanga, ICC-01/04-01/06, សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញា អំពីការទទួលយកកំណត់ហេតុសាក្សីដែលបានកត់ត្រាទុកមុនៗរបស់សាក្សីពីររូប, ១៥ មករា ២០០៩, កថាខ័ណ្ឌទី១៧ ។

## III. ការអនុវត្តគោលការណ៍ខាងលើនៅចំពោះមុខ អ.វ.ត.ក

៣០- ក្នុងសំណុំរឿងលេខ០០១ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សំគាល់អំពីគោលការណ៍ទាំងនេះ ដែលបានថ្លែងដោយ ECtHR និង ICTY ។ ក្នុងខណៈដែលអង្គជំនុំជម្រះនេះបានបដិសេធមិនទទួលយកកំណត់ហេតុដែលពុំបានស្បថរបស់បុគ្គល២រូបដែលមានភ័ស្តុតាងអំពីសកម្មភាព និងទង្វើរបស់ជនជាប់ចោទ[49] ក៏អង្គជំនុំជម្រះសាលាដំបូងបានទទួលយកកំណត់ហេតុសាក្សីចំនួន១៤ និងបានអនុញ្ញាតឲ្យគូភាគីផ្តល់យោបល់លើកំណត់ហេតុទាំងនោះ[50]។

៣១- សហព្រះរាជអាជ្ញាសន្និដ្ឋានថា គេមានមូលហេតុចាប់បង្ខំនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងការយល់ស្រប ដើម្បីទទួលយកកំណត់ហេតុរបស់សាក្សីនៅក្នុងករណីនេះ ដោយពុំចាំបាច់ឲ្យសាក្សីទាំងអស់មកបង្ហាញខ្លួនសម្រាប់ការសួរដេញដោល។ ការទទួលយកកំណត់ហេតុដោយអនុលោមតាមគោលការណ៍អន្តរជាតិដូចបានលើកឡើងពីខាងលើ គឺស៊ីសង្វាក់ទាំងស្រុងជាមួយនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ និងភាពសមស្របដែរទាក់ទិននឹងនីតិវិធីច្បាប់រដ្ឋប្បវេណីជាធរមាននៅ អ.វ.ត.ក[51]។ នីតិវិធីនេះដាក់ការបញ្ជាក់យ៉ាងសំខាន់ទៅលើការប្រើប្រាស់ភ័ស្តុតាងជាលាយលក្ខណ៍អក្សរដែលប្រមូលបានក្នុងពេលនៃកិច្ចស៊ើបសួរ[52]។ កិច្ចស៊ើបសួរត្រូវគេបានរំពឹងទុកថា បានធ្វើឡើងយ៉ាងត្រឹមត្រូវពីព្រោះថា នៅពេលបិទកិច្ចស៊ើបសួរ ភ័ស្តុតាងពាក់ព័ន្ធទាំងអស់ត្រូវបានដាក់នៅក្នុងកំណត់ហេតុ[53]។ លក្ខណៈពិសេសជាគន្លឹះនៃប្រព័ន្ធនេះគឺថា ខណៈដែលជនសង្ស័យមាន

---

[49] សំណុំរឿងលេខ០០១: សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភ័ស្តុតាង, ២៦ ឧសភា ២០០៩, ឯកសារលេខ E43/4, កថាខ័ណ្ឌទី១៣-១៦ ។

[50] សាលក្រម, ២៦ កក្កដា ២០១០, ឯកសារលេខ E188, កថាខ័ណ្ឌទី១៩ ។

[51] ដូចអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានកត់សំគាល់ដែរ គឺថាវិធាន៩២ស្ទួន គឺថ្លឹងថ្លែងនូវផលប្រយោជន៍របស់គូភាគីនានា និងថែងពីលក្ខខណ្ឌដ៏តឹងរ៉ឹងសម្រាប់ភាពអាចទទួលយកភ័ស្តុតាងក្នុងទម្រង់ជាលាយល័ក្ខណ៍អក្សរ: រដ្ឋអាជ្ញា ទល់នឹង Milosevic, IT-02-54-AR73.2, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃភ័ស្តុតាងរបស់អ្នកស៊ើបអង្កេតរបស់រដ្ឋអាជ្ញា, ៣០ កញ្ញា ២០០២, កថាខ័ណ្ឌទី១៨-១៩ ។

[52] សូមអាន ជាឧទាហរណ៍ Jerome de Hemptinne, 'ការបង្កើតអង្គស៊ើបអង្កេតនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ - ជម្រើសមួយដែលត្រូវតាមរកឲ្យបាន? ទិនានុប្បវត្តិអំពីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ 5 (2007), ត្រង់ 407 ។

[53] សៀវភៅរបស់លោក Merryman, J., ប្រព័ន្ធច្បាប់ស៊ីវិល ឆ្នាំ១៩៦៩ ត្រង់ទំព័រទី១២៩ ។

សិទ្ធិទទួលបានតំណាងផ្នែកច្បាប់ ការណ៍នេះ "មិនមែនមានន័យថា អ្នកការពារក្ដីមានសេរីភាពដោយគ្មានព្រំដែនកំណត់ ទៅលើការសួរសាក្សីរបស់គូបដិបក្ខនោះឡើយ"[54]។

៣២- ក្នុងករណីនេះ ភ័ស្ដុតាងត្រូវបានប្រមូល និងត្រួតពិនិត្យឡើងវិញដោយសហចៅក្រមស៊ើបអង្កេត ដែលតម្រូវឲ្យអនុវត្តកិច្ចស៊ើបសួរ "ដោយគ្មានលំអៀង មិនថាភ័ស្ដុតាងនោះជាភ័ស្ដុតាងដាក់បន្ទុក ឬដោះបន្ទុក"[55]នោះទេ។ កិច្ចស៊ើបសួរត្រូវបានគ្រប់គ្រងដោយគោលបំណងនៃការស្រាវជ្រាវស្វែងរកការពិត ទាក់ទិននឹងការអះអាងចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ជាជាងប្រមូលតែភ័ស្ដុតាងដាក់បន្ទុកប្រឆាំងនឹងជនជាប់ចោទ[56]។ ស.ច.ស មិនជាប់កាតួកិច្ចទៅនឹងដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទេ សូម្បីតែទាក់ទិននឹងជនដែលត្រូវចោទ ឬទាក់ទិននឹងសេចក្ដីសន្និដ្ឋានបិទការស៊ើបសួររបស់ខ្លួនក៏ដោយ[57]។

៣៣- យោងតាមស្មារតីនៃគោលការណ៍អន្តរជាតិដូចបានលើកឡើងនៅក្នុងផ្នែកII, និងនីតិវិធីជាធរមាននៅចំពោះមុខ អ.វ.ត.ក នៅក្នុងការវាយតម្លៃលើសំណើរបស់មេធាវីការពារក្ដី សម្រាប់ការសួរសាក្សី អង្គជំនុំជម្រះសាលាដំបូងគួរគិតគូទៅលើសេចក្ដីពិចារណាដូចខាងក្រោម ៖

(ក) កាតព្វកិច្ច ក្នុងការធានាចំពោះភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីទាំងមូល រួមទាំង ការគោរពចំពោះការពិនិត្យ និងថ្លឹងអំណាចដែលបានផ្ដល់ជូនដោយកិច្ចស៊ើបសួរ។

(ខ) កាតព្វកិច្ចដូចមានចែងក្នុងអនុវិធាន២១(១) ក្នុងការរក្សាតុល្យភាពរវាងគូភាគី និងការពារផលប្រយោជន៍របស់ជនរងគ្រោះ។

---

[54] *ក្នុងឯកសារដដែលដូចខាងលើ* ។

[55] អនុវិធាន៥៥(៥) ។

[56] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភ័ស្ដុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម, ១២ វិច្ឆិកា ២០០៩, ឯកសារលេខ D164/3/6, កថាខ័ណ្ឌទី៣៥ ។ សូមអានផងដែរ Francis Pakes, *យុត្តិធម៌ព្រហ្មទណ្ឌដែលអាចប្រៀបធៀបបាន*, 2004, ត្រង់ទំព័រទី៨០ ។

[57] អនុវិធាន៥៥(៤) និង ៦៧(១) ។

(គ) វិសាលភាពដែលភស្តុតាងត្រូវបញ្ជាក់ពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទ រួមទាំងការចូលរួមរបស់ពួកគេនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម។

(ឃ) វិសាលភាពដែលភស្តុតាងជាប្រភេទមានអានុភាពចេះតែកើនឡើង និងដែលបញ្ជាក់ទៅនឹងភស្តុតាងផ្ទាល់មាត់តែមួយគត់ ដែលនឹងត្រូវសួរដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ។

(ង) ភាពជឿទុកចិត្តបាន និងតម្លៃភវនីយភាពនៃកំណត់ហេតុ; និង

(ច) ភាពជឿទុកចិត្តបានចំពោះសាក្សីដែលត្រូវមកបង្ហាញខ្លួននៅចំពោះមុខតុលាការ និងការប៉ះពាល់ទៅនឹងរយៈពេលរួមរបស់សវនាការ។

៣៤- ការទទួលយកកំណត់ហេតុសាក្សីដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ត្រូវបានដាក់នៅក្នុងសំណុំរឿងជាង៣ឆ្នាំមកនេះ ក្នុងអម្លុងពេលដែលអយ្យការ និងមេធាវីការពារក្តី មានលទ្ធភាពពេញលេញទៅលើសំណុំរឿងនេះ។ ភាគីនានាអាចមើលគ្រប់ផ្នែកនៃភស្តុតាងដែលគេបានបន្ថែមនៅក្នុងសំណុំរឿង និងអាចចូលរួមក្នុងកិច្ចស៊ើបសួរ តាមរយៈការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរនានា និងការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ ហេតុដូច្នេះ គេរំពឹងទុកថាពួកគេគួរតែអនុវត្តនូវការប្រុងប្រយ័ត្នឲ្យបានខ្ពស់ ក្នុងការជ្រើសយកសាក្សីទាំងឡាយដែលគេមានបំណងចង់ឲ្យមកសួរដេញដោលនៅពេលសវនាការ។ ការអនុញ្ញាតឲ្យជនជាប់ចោទដែលជំនះចង់សួរដេញដោលសាក្សីច្រើនរយនាក់ ដែលកំណត់ហេតុរបស់ពួកគាត់មានរួចស្រេចហើយក្នុងសំណុំរឿង មិនថាកំណត់ហេតុទាំងនោះទាក់ទិននឹងអំពើរបស់ជនជាប់ចោទ ឬផ្នែកណាមួយនៃសំណុំរឿង ឬមិនថា កំណត់ហេតុទាំងនោះត្រូវបានបញ្ជាក់ដោយភស្តុតាង*ផ្ទាល់មាត់* និង/ឬ ជាលាយល័ក្ខណ៍អក្សរ និងមិនថាមានផលប៉ះពាល់ដល់រយៈពេលនៃសវនាការប៉ុន្មានទេ គឺវាដូចគ្នានឹងការអនុញ្ញាតឲ្យជនជាប់ចោទធ្វើឲ្យខូចដល់កិច្ចដំណើរការនីតិវិធី និងរំលោភបំពានដំណើរការរបស់តុលាការ។ វាក៏នឹងធ្វើឲ្យខូចដល់សិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលមួយសមរម្យរបស់ជនជាប់ចោទដទៃទៀត និងផលប្រយោជន៍របស់ជនរងគ្រោះក្នុងការអនុវត្តដោយប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីដែរ។

៣៥- អង្គជំនុំជម្រះគួរតែចាប់យកគោលការណ៍ណែនាំពីវិធាននានាដែលបានបង្កើតក្នុងកំរិតអន្តរជាតិ ហើយកែឆ្នៃថែមថយឲ្យទៅជានីតិវិធីដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ។ ឧទាហរណ៍ លក្ខខណ្ឌតម្រូវសម្រាប់ការបញ្ជាក់អំពីកំណត់ហេតុសាក្សី នឹងមិនសមស្របឡើយ ចំពោះកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំងឡាយណាដែលបានផលិតឡើង នៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ។

៣៦- ដូចបង្ហាញយ៉ាងច្បាស់តាមរយៈសេចក្តីសង្ខេបអំពីសាក្សី និងឯកសាររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៨០ ភាគច្រើននៃសាក្សីដែលកំណត់ហេតុរបស់ពួកគេ ត្រូវបានបញ្ជូនទៅហើយនោះ មិនបានផ្តល់សក្ខីកម្មអំពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទ ឬអ្នកក្រោមបង្គាប់ផ្ទាល់របស់ពួកគេទេ គឺធ្វើចំពោះតែព្រឹត្តិការណ៍អំពីមូលដ្ឋានឧក្រិដ្ឋកម្ម ផលប៉ះពាល់ទៅលើជនរងគ្រោះ និងបញ្ហាពាក់ព័ន្ធដទៃទៀតដូចជា គោលនយោបាយ, រចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងគ្នា និងអត្ថិភាពនៃផែនការឧក្រិដ្ឋកម្មរួមតែប៉ុណ្ណោះ។ ការអនុវត្តច្បាប់យុត្តិសាស្ត្ររបស់ ICTY គឺថាភាគច្រើនបំផុតនៃកំណត់ហេតុសាក្សីគួរតែបានទទួលយក ដោយពុំចាំបាច់មានលក្ខខណ្ឌណាមួយតម្រូវសាក្សីចូលមកបង្ហាញខ្លួនសួរដេញដោលទេ។ នៅក្នុងការបង្កើតបញ្ជីឈ្មោះសាក្សីស្នើឡើងសម្រាប់សវនាការរបស់ខ្លួន សហព្រះរាជអាជ្ញាបានយកចិត្តទុកដាក់ ដើម្បីកំណត់អត្តសញ្ញាណសាក្សីទាំងអស់ ដែលសហព្រះរាជអាជ្ញាជឿថា អាចផ្តល់ភស្តុតាងភរនីយភាពទាក់ទិននឹងអំពើ និងសកម្មភាពរបស់ជនជាប់ចោទ។ ការពិតមិនមែនជាគោលជំហររបស់សហព្រះរាជអាជ្ញាទេ ដែលថាភស្តុតាងសក្ខីកម្មជាគន្លឹះនានាទាក់ទិននឹងអំពើ និងសកម្មភាពរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មនានា គួរបានទទួលយកក្នុងទម្រង់ជាលាយលក្ខណ៍អក្សរនោះឡើយ បើសិនជាសាក្សីអាចឲ្យគេរកបាន។ កង្វល់ជាចំបងរបស់សហព្រះរាជអាជ្ញា គឺការសម្រួលដល់សវនាការ ដើម្បីឲ្យមានភាពត្រឹមត្រូវ និងបញ្ចប់ក្នុងរយៈពេលមួយសមរម្យ។

## IV. បញ្ហានីតិវិធី

៣៧- ដោយពិចារណាពីទំហំ និងភាពស្មុគស្មាញចំពោះរឿងក្តីនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា វាមិនមែនជាទម្លាប់នៃការអនុវត្តដែលត្រូវសម្រេចអំពីកំណត់ហេតុសាក្សីទាំងអស់ នៅក្នុងដំណាក់កាលដំបូងនេះទេ។ សហព្រះរាជអាជ្ញាសូមអញ្ជើញអង្គជំនុំជម្រះធ្វើការដោះស្រាយលើភស្តុតាងនេះជា

ដំណាក់កាលៗ តាមការចេញសេចក្តីសម្រេចនានា អំពីការទទួលយកកំណត់ហេតុ (និងថាតើសាក្សីត្រូវឲ្យចូលបង្ហាញខ្លួន ដើម្បីសួរដេញដោលឬទេ) មុននឹងចាប់ផ្តើមដំណាក់កាលពាក់ព័ន្ធនិមួយៗនៃកិច្ចដំណើរការនីតិវិធី[58]។ ការណ៍នេះនឹងបង្កលក្ខណៈឲ្យគូភាគីបានផ្តល់ជូននូវជំនួយផ្សេងៗ ដល់អង្គជំនុំជម្រះតាមរយៈការផ្តល់ព័ត៌មានផ្សេងៗបន្ថែមទៀតដែលអាចជាការចាំបាច់។

៣៨- សហព្រះរាជអាជ្ញាទទួលស្គាល់ផងដែរថា អង្គជំនុំជម្រះអាចត្រូវការអនុម័តនូវនីតិវិធីខុសៗគ្នាផ្អែកលើទម្រង់ និងដើមកំណើតនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរ។ ឧទាហរណ៍ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ ដែលបានផលិតដោយអ្នកស៊ើបអង្កេតដែលបំពេញការងាររបស់ខ្លួននៅក្រោមការគ្រប់គ្រងរបស់ ស.ច.ស មានតម្លៃភស្តុតាងនិយភាព និងសញ្ញាបង្ហាញអំពីភាពជឿទុកចិត្តបានច្បាស់លាស់ និងដែលបានធ្វើឡើងដោយមានសម្បថ បានកត់ត្រាដោយមន្ត្រីតុលាការ បានចុះហត្ថលេខាដោយសាក្សី និងអមមកជាមួយនឹងខ្សែអាត់សម្លេង។ ការពិចារណាដូចគ្នានេះដែរគួរអនុវត្តចំពោះប្រតិចារិកនៃសំណុំរឿងលេខ០០១ ឬកំណត់ហេតុពីមុនៗដែលបានអានជូនសាក្សីក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ និងដែលសាក្សីបានស្បថថាពិត។

៣៩- ខណៈដែលកំណត់ហេតុជាច្រើន ត្រូវបានប្រមូលមុនពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ក៏មានសញ្ញាបង្ហាញខ្លាំងក្លាផងដែរអំពីភាពជឿទុកចិត្តបាន (ដូចជា កំណត់ហេតុធ្វើដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឬអ្នកស្រាវជ្រាវជាន់ខ្ពស់ផ្សេងៗដែលជាញឹកញាប់ ត្រូវបានធ្វើប្រតិចារិកចេញពីខ្សែអាត់សម្លេង)។ អង្គជំនុំជម្រះគួរពិចារណាអំពី: i) តើការបញ្ជាក់ដូចមានចែងក្នុងអនុវិធាន៩២ស្ទួន(ខ)នៃវិធានរបស់ ICTY នឹងសមស្របឬទេ ឬ ii) តើកំណត់ហេតុអាចត្រូវបានទទួលយកឬទេ ប្រសិនបើសាក្សីបានស្លាប់ ឬមិនអាចរកឃើញដោយការព្យាយាមសមហេតុផលដូចមានចែងក្នុងវិធាន៩២*ស្ទួន៤*នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY ។

៤០- ដើម្បីឲ្យនីតិវិធីទាំងនេះមានលក្ខណៈសាមញ្ញ អង្គជំនុំជម្រះសាលាដំបូងអាចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីទទួលយកកំណត់ហេតុសាក្សីជាបណ្តោះអាសន្ន ដោយត្រូវមានការបញ្ជាក់ពីនីតិវិធី

[58] រដ្ឋអាជ្ញា ទល់នឹង Brdanin និង Talic, IT-99-36-T, ច្បាប់ចេញផ្សាយជាសាធារណៈនៃសេចក្តីសម្រេចជាសម្ងាត់ស្តីពីភាពអាចទទួលបាននៃកំណត់ហេតុសាក្សីដូចមានចែងក្នុងវិធាន៩២ស្ទួន ចុះថ្ងៃទី១ ខែឧសភា ឆ្នាំ២០០២, ២៣ ឧសភា ២០០២, កថាខ័ណ្ឌទី៣-៧ ។

មួយដែលបានប្រើញឹកញាប់ដោយតុលាការ ICTY[59]។ យុទ្ធសាស្ត្រស្រដៀងគ្នានេះ ក៏អាចយកមកអនុវត្តផងដែរ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថាសមស្រប ដើម្បីស្វែងរកការបញ្ជាក់ពីអ្នកស្រាវជ្រាវអំពីកាលៈទេសៈនៃការយកកំណត់ហេតុ ឬក៏តម្រូវឱ្យដាក់តឹកតាងបន្ថែម អំពីភាពជឿទុកចិត្តបាន ដូចជាកំណត់ត្រា និងខ្សែអាត់សម្លេងក្នុងពេលដំណាលគ្នា។

## V. សេចក្តីសន្និដ្ឋាន

៤១- ដូចមូលហេតុរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាសូមស្នើអង្គជំនុំជម្រះសាលាដំបូង ដូចតទៅ៖

(ក) ប្រកាសថា៖

i. គ្មានសិទ្ធិដាច់ខាតក្នុងការកោះហៅសាក្សីទាំងអស់ ដែលកំណត់ហេតុរបស់ពួកគេ កំពុងតែស្នើបញ្ចូលជាភ័ស្តុតាង និង

ii. កំណត់ហេតុសាក្សីទាំងអស់ត្រូវបានទទួលយក ដោយហេតុថា កំណត់ហេតុទាំងនោះមានការពាក់ព័ន្ធ និងមានតម្លៃភស្តុតាងភាព។

(ខ) សម្រេចលើភាពចាំបាច់សម្រាប់សាក្សីបង្ហាញខ្លួននៅពេលសវនាការ សម្រាប់សួរដេញដោល នៅពេលចាប់ផ្តើមដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធនានា។

59 រដ្ឋអាជ្ញា ទល់នឹង Karadzic, IT-95-5/18-PT, សេចក្តីសម្រេចលើញត្តិលើកទីបីរបស់រដ្ឋអាជ្ញាសុំឱ្យទទួលយកកំណត់ហេតុ និងប្រតិចារិកនៃភ័ស្តុតាងនានា ជំនួសសក្ខីកម្មដោយ*ផ្ទាល់មាត់* អនុលោមតាមវិធាន៩២ស្ទួន (សាក្សីសម្រាប់ឱ្យទីក្រុងសៀរ៉ាចេវ៉ូ), ១៥ តុលា ២០០៩, កថាខ័ណ្ឌទី៩ ។ រដ្ឋអាជ្ញា ទល់នឹង Popovic និងគូកន., សំណុំរឿងលេខ IT-05-88-T, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញាសុំឱ្យទទួលយកភ័ស្តុតាងលាយលក្ខណ៍អក្សរជំនួសឱ្យសក្ខីកម្មដោយ*ផ្ទាល់មាត់* អនុលោមតាមវិធាន៩២ស្ទួន, ១២ កញ្ញា ២០០៦, កថាខ័ណ្ឌទី១៩-២១។ រដ្ឋអាជ្ញា ទល់នឹង Martic, សំណុំរឿងលេខ IT-95-11-T, សេចក្តីសម្រេចលើញត្តិស្នើសុំជាសម្ងាត់របស់រដ្ឋអាជ្ញាសុំឱ្យទទួលយកភ័ស្តុតាងលាយលក្ខណ៍អក្សរ អនុលោមតាមវិធាន៩២ស្ទួន នៃវិធាននានា, ១៦ មករា ២០០៦, កថាខ័ណ្ឌទី១១, ៣៧ ។

(គ) យកគោលការណ៍ណែនាំទូទៅនៃវិធាន៩២ស្ទួន និងករណីយុត្តិសាស្ត្ររបស់ ICTY ដោយសម្របទៅនឹងកាលៈទេសៈជាក់លាក់របស់ អ.វ.ត.ក រួមទាំងការពិតដែលថា ភស្តុតាងនៅក្នុងសំណុំរឿងលេខ០០២ ត្រូវបានប្រមូលនៅក្នុងកិច្ចស៊ើបសួរដោយមិនលំអៀង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ | **លោក យ៉េត ចរិយា** សហព្រះរាជអាជ្ញារង | ភ្នំពេញ | |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | |